រឿង

# ទសជាតក៏សង្ខេប

UDDHIST INSTIT



២៤០.
១៣៩

# ស្នាដៃនេះ

កើតឡើងពីកិច្ចសហការគ្នា រវាង

**ពុទ្ធសាសនបណ្ឌិត្យ** និង **បណ្ណាល័យអេឡិចត្រូនិចខ្មែរ**

ក្នុងគោលបំណងយ៉ាងមុតមាំដើម្បីថែរក្សា ការពារ កុំឲ្យបាត់បង់តទៅទៀត

ព្រមទាំងផ្សព្វផ្សាយស្នាដៃ-ឯកសារទាំងនេះ

សម្រាប់សាធារណជនប្រើប្រាស់ដោយមិនគិតកម្រៃ។

សូមថ្លែងអំណរគុណដល់

**អង្គការរីស្ស្ហូ កូសី-កៃ  វិទ្យាស្ថានបើកទូលាយ**

**ករុណាខ្មែរ និង មូលនិធិខ្មែរសម្រាប់ការសិក្សា**

ដែលបានគាំទ្រគម្រោងការស្នាដៃនេះ សម្រាប់ទុកក្នុងបណ្ណាល័យអេឡិចត្រូនិច។

Buddhist Institute of Ministry of Cult and Religion and eLibrary of Cambodia have made a cooperative effort to digitalize books and manuscripts in order to preserve our Cambodian literary heritage. This will promote and provide easy, instant access, free of charge to the public and future generations to come.

A sincere thank you to our generous supporters: Rissho Kosei-Kai, Open Institute, Karuna Cambodia and Cambodian Education Excellence Foundation, who made this endeavor possible.

www.budinst.gov.kh    www.elibraryofcambodia.org

២៤០.១៣៩

# ទសជាតក៍សង្ខេប

(តាមច្បាប់សាស្ត្រាស្ទឹករែត)

ចំឡងផ្ទៀងផ្ទាត់ដោយ

ស្តើង - ឈួរ

ការពិនិត្យ ធីជ និវេទន៍

របស់

លី - ធាមតេង

គណៈកម្មការស្រាវជ្រាវអក្សរសាស្ត្រ

BUDDHIST INSTITUTE LIBRARY
៦៥៤០/០២

ផ្សាយចេញពី

រោងពុម្ព **ស៊ីវ - ហេង**

លេខ ១១៥ វិថី៩កញ្ញា ទេ ៣ - ៥៨

(អតីតផ្លូវអូរឫស្សី) ភ្នំពេញ

រក្សាសិទ្ធិ

ព.ស. ២៥០៨ គ.ស. ១៩៦៥

# រឿង

# ទសជាតក៍សង្ខេប

មាន :


១ — តេមិយជាតក (នេក្ខម្មបារមី) ទំព័រ ១

២ — ជនកជាតក (វិរិយបារមី) — ១២

៣ — សុវណ្ណសាមជាតក (មេត្តាបារមី) — ២៥

៤ — នេមិរាជជាតក (អធិដ្ឋានបារមី) — ៣២

៥ — មហោសថជាតក (បញ្ញាបារមី) — ៣៧

៦ — ភូរិទត្តជាតក (សីលបារមី) — ៤៣

៧ — ចន្ទកុមារជាតក (ខន្តីបារមី) — ៦៥

៨ — នារទជាតក (ឧបេក្ខាបារមី) — ៧២

៩ — វិធុរជាតក (សច្ចបារមី) — ៧៨

១០ — វេស្សន្តរជាតក (ទានបារមី) — ៨៨

# និវេទន៍

—០០—

តាមធម្មតា ដើម្បីឲ្យបានយល់ច្បាស់ពីអត្ថបទរឿងណាមួយ អ្នកអានឬអ្នកសិក្សា តោងតែដេញដោលរកដើមកំណើតរឿងទាំងនោះ ឲ្យឃើញជាមុន រួចហើយពិចារណារកខ្លឹមសារនៃរឿងនោះទៀត ។ អាស្រ័យហេតុនេះ ខ្ញុំសូមធ្វើជាសេចក្ដីសង្កេតជាដើមរឿង ហៅថា "និវេទន៍" ជាជំនួយសិក្សាដូចតទៅ ៖

## ១– ប្រភព.–

រឿងទសជាតក៍ ពុំមែនជារឿងមានកំណើតនៅស្រុកអាយ ដូចរឿងក្នុងបញ្ញាសជាតកឡើយ គឺមានប្រភពដើមនៅក្នុងគម្ពីរព្រះត្រៃបិដក ដែលតែងឡើងជាភាសាបាលីសុទ្ធ ៗ គឺថា ព្រះត្រៃបិដកចែកចេញជាបីផ្នែក គឺព្រះវិន័យ ព្រះសូត្រ និង ព្រះអភិធម្ម ។ ក្នុងផ្នែកទាំងបីនេះ ព្រះសូត្រជាផ្នែកអធិប្បាយពន្យល់ពីគោលគំនិតផ្សេង ៗ ជា

ការទាក់ទាញចិត្តអ្នកស្រុកឲ្យជ្រះថ្លាក្នុងពុទ្ធទុកាល ។ ម្លោះ
ហើយ ព្រះសូត្រមានចេញជាក្រុមច្រើនទៀតហៅថា
"និកាយ" ។ ក្នុងបណ្ដានិកាយទាំងនេះ មាននិកាយមួយ
ឈ្មោះថា "ខុទ្ទកនិកាយ" បែកចេញជាពួករឿងមួយពួកៗ ទៅ
ទៀតហៅថា «និបាត» ។ ក្នុងបណ្ដានិបាតទាំងអស់មាន
និបាតមួយឈ្មោះ "មហានិបាត" មានដំណើររឿងចំនួន
១០ ; ហេតុនេះ គេច្រើនហៅគម្ពីរនេះតាមការសំគាល់
ថាមានដប់រឿងដូច្នេះ ទើបគេសន្មតនាមថ្មីឲ្យមហានិបាត
នេះថា "ទសជាតក៍" ដែលប្រែថា ១០ រឿង ។
អ្នកស្រុកខ្មែរអាចកាត់បន្ថិចទៀត ទៅជា ទសជាតក៍ ។

ប៉ុន្តែអត្ថបទដើម ជាបាលីសុទ្ធដូចមានចម្លងគម្ពីរមកនេះ
ស្រាប់ ។ លុះអ្នកប្រាជ្ញខ្មែរយើង រៀនសូត្រចេះដឹង
ហើយ ក៏មានបំណងចង់ឲ្យអ្នកស្រុកខ្លួនទៅដែលមិនចេះភាសា
បាលីបានក្រេបរសជាតិរឿងទាំងនេះផង លោកក៏បកប្រែ

ហើយកែងសម្រួលជាថ្មី កើតជាគម្ពីរភាសាខ្មែរនេះឡើង ដោយមានបញ្ញាលខ្វះតាមគតិនិយមនៃអ្នកស្រុកខ្មែរផង ៗ

## ២– ប្រភេទ.—

–រឿងទសជាតក៍ ជារឿងពុទ្ធនិយមសុទ្ធសាធជាងរឿងពុទ្ធនិយមឯទៀត ១ ព្រោះថារឿងនេះមានប្រភពដើមនៅគម្ពីរព្រះត្រៃបិដកផ្ទាល់ ៗ ម្យ៉ាងទៀត ផ្នែកព្រះសូត្រជាផ្នែកអធិប្បាយពន្យល់ ឲ្យអ្នកស្រុកចុះចិត្តគំនិតក្នុងពុទ្ធចក្រទម្ងោះហើយ សាច់រឿងទាំងស្រុង ក៏ត្រូវតែពន្យល់បញ្ជាក់លាស់ក្នុងទ្រឹស្តីព្រះពុទ្ធដែរ ដូចជាការលើកយកអំពើល្អ អំពើអាក្រក់ គឺជំនឿកម្ម នឹងផលយកមកធ្វើជាគោលជាដើម ៗ

រឿងក៏ទាំង ១០ នេះ ពន្យល់ពីការសាងបារមីទាំង ១០ ឬ ទសបារមី របស់ព្រះពោធិសត្វ គឺថាក្នុង ១ រឿង ពន្យល់ពីបារមីមួយ ដូចតាក់ងរឿងដែលដាក់នៅទំព័របន្ទាប់នោះ បង្អួលបង្ហាញស្រាប់ ៗ និយាយជាសរុបគឺ ពោធិសត្វ

ទាំងឡាយទឹងត្រាស់ដឹងបាន លុះណាតែបានប្រកបដោយ បារមីគឺការបង្ហាត់ចិត្ត អប់រំចិត្តឲ្យលុះសម្រេចបានតាមចំណង់ គោលឧត្តមគតិទាំង ១០ ។

## ៣- ខ្លឹមសារ

ដោយរឿងទាំង ១០ នេះ សុទ្ធតែមានបំណងពន្យល់អំពី ការសាងបារមីទាំង ១០ របស់ព្រះពោធិសត្វនោះ គោលគំនិតទាំងនេះក៏ហុចប្រយោជន៍ឲ្យដល់អ្នកអានច្រើនដែរ គឺណែនាំឲ្យអ្នកអានស្គាល់គុណ - ស្គាល់ទោស ស្គាល់តម្រាយទៅកាន់ផ្លូវល្អ អាចសាងខ្លួនឲ្យទៅជាអ្នកត្រឹមត្រូវល្អប្រពៃបាន ជាពិសេសគឺគន្លងទាំងឡាយ ដែលព្រះពោធិសត្វទ្រង់បានត្រាយទុកមក គន្លងដំណើររង្ហាត់កន្លងសង្ការរបស់លោក ។ ទោះបីជាមានលាយស្រាយខ្លះ ព្រោះរឿងឃ្លាតទៅតាមការតែងក៏ដោយ ក៏គង់នៅមានខ្លឹមសារល្អៗច្រើនដែរ ។

អាស្រ័យដោយសារប្រយោជន៍ទាំងនេះ ទើបបានអ្នកស្រុកយើង និយមរឿងនេះ គ្រប់ភូមិស្រុកទាំងអស់ រហូតសព្វថ្ងៃទៅជារឿងសំរាប់សិក្សានៅមធ្យមភូមិផង ។ ។

ភ្នំពេញ ២១ មករា ១៩៦៥

**លី-ធាមតេង**

# ១ – រឿងតេមិយជាតក

នមោ តស្ស ភគវតោ អរហតោ សម្មា សម្ពុទ្ធស្ស ។

មា បណ្ឌិតាចាយំ វិភាវយាតិ ឥទំ សត្ថា ជេតវនេ វិហរន្តោ មហាភិនិក្ខមនបារមី អារព្ភ កថេសិ ។ សត្ថា នោះ សត្ថវាហោ សត្ថ-ណាយកោ គឺព្រះអង្គទ្រង់ជានាយក តែងដឹកនាំសត្វផងទាំងឡាយ ប្រមូលបញ្ចូលទៅកាន់ផ្លូវអម្រឹតបូរីស្រីមហានគរ ស្ដេចគង់សម្រាន្តខាននៅមហាជេតពន ។ អារ-ព្ភា អារម្មណំ កត្វា ទើបព្រះអង្គធ្វើជាហេតុជាអារ-ម្មណ៍បន្តិច មហាភិនិក្ខមនបារមី ទីងបំពេញនូវមហាភិនិស្ក្រមណ៍ កថេសិ នោះ ធម្មំ ទេសេសិ ទើបព្រះអង្គសំដែងថ្វាយនូវព្រះធម៌ទេសនា ឥទំ តេមិ-យ ជាតកំ ទីងនិទានដំណើរកាលព្រះអង្គយកកំណើត

កើតជាពោធិសត្វមួយព្រះអង្គទ្រង់ព្រះនាមតេមិយនេះ អានិកាថាបទេន អត្តនា ឧបលិទ្ធិំ ទើបព្រះអង្គកត់សំគាល់ជាដើមបទកំណត់ព្រះគាថានេះជាដើម មា បណ្ឌិតា ជាយំ វិភាវយាតិ នេះហៅថាជាដើមបទទាំងឡាយ ។

ឯកាធិវសំ ហិ ភិក្ខុ ធម្មសភាយំ សន្និសិន្នា អាគារវេត្វា មហាភិនិក្ខមនបារមី វណ្ណយន្តិ និសីទិំសុ បពិត្រអើយ មានសម័យថ្ងៃមួយនោះ អស់ពពួកភិក្ខុសង្ឃអង្គអរហន្តខីណាស្រពផងទាំងឡាយ ទៅជុំគ្នាក្នុងធម្មសភាសាលា ភិក្ខុដ៏ជាចាស់ស្ថិតនៅដើមកេសន៍ មានពុទ្ធដីកាទៅកាន់ភិក្ខុគម្ពោះផងទាំងឡាយថា : ភិក្ខុទេ ភិក្ខុផងទាំងឡាយអើយ ព្រះមានបុណ្យដ៏ជាអម្ចាស់នៃយើងនេះព្រះអង្គមានបារមីបុព្វទុកាពក្រៃ តែអ្នកឯណាឲ្យស្មើនឹងព្រះអង្គគ្មាន ។ ឯពាក្យនោះក៏មិនបាត់

ស្ងាត់ជ្រាបដល់ព្រះសោតទិព្វនៃព្រះពុទ្ធជាអម្ចាស់ ទើប
ព្រះអង្គទ្រង់ព្រះចិន្តាគិតពិចារណា ថាបើអញ់តថាគតពុំបាន
ទៅស្ដាប់ រីកំណើតអញតថាគតជាព្រះគេមិយនេះ រានឹងកំ
បាំងបាត់ស្ងាត់ទៅ បើតថាគតទៅស្ដាប់ រីកំណើតអញតថា
គតជាគេមិយនេះ រានឹងដឹងពុទ្ធូវទ័រជាអស្ចារ្យ, ព្រះអង្គគិតពិ-
ចារណាដូច្នោះហើយ ទើបព្រះអង្គយាងទៅកាន់ដំនុំសង្ឃផង
ទាំងឡាយ ទើបព្រះអង្គដណ្ដឹងថា : អាវុសោ ម្នាល
ភិក្ខុផងទាំងឡាយអើយ អ្នកស្រដីនេះតើនូវពាក្យអ្វី ? ។
៩មាយ ញាមាតិវុត្ត ទើបភិក្ខុផងទាំងឡាយក្រាបទូល
ព្រះពុទ្ធដីកាថា : កតេ្ត កកវា បពិត្រព្រះមានព្រះភាគ
រីយើងទាំងឡាយ ស្រដីសរសើរអំពីរូបស្រីនោះផងអង្គមានទេ-
ស្រដីនេះសរសើរតែអំពីបារមីនៃព្រះមានបុណ្យជាអស្ចារ្យក្រៃ
ទីងរកអ្នកឯណាប្រៀបផ្ទឹមពុំបាន, ទើបព្រះមានបុណ្យទ្រង់
ជ្រាបដូច្នោះហើយ ព្រះអង្គក៏សំដែងនូវព្រះធម៌ទេសនាឲ្យ

អស់ភិក្ខុផងទាំងឡាយស្តាប់ សូត្រជាបទព្រះបាលីថា :

អតីតេ ភិក្ខវេ ពារាណសិយំ កាសិករាជា ឆាម ធម្មេន សមេន រជ្ជំ ការេសិ ។ ភិក្ខវេ ម្នាលភិក្ខុផងទាំងឡាយអើយ កាលពីអតីតកន្លងយូរលង់ណាស់ទៅហើយនោះ មានមហាក្សត្រាធិរាជ មួយព្រះអង្គទ្រង់ព្រះនាមព្រះបាទ កាសិករាជសោយរាជសម្បត្តិក្នុងនគរពារាណសីប្រកបដោយគន្លងធម៌ដ៏ប្រសើរ ព្រះអគ្គមហេសីទ្រង់ព្រះនាមនាង ចន្ទាទេវី ជាធំកន្លងលើសស្រីព្រះស្នំ មួយម៉ឺនប្រាំមួយពាន់ រីឯស្រីទាំងមួយម៉ឺនប្រាំមួយពាន់រកកូនប្រុសកូនស្រីមួយគ្មាន ។ រីពោធិសត្វកាលមុនព្រះអង្គសោយរាជ្យសម្បត្តិក្នុងនគរពារាណសី បានម្ភៃឆ្នាំហើយ ហេតុតែព្រះអង្គធ្វើអំពើមិនប្រកបដោយធម៌ ទៅសោយទុក្ខក្នុងឧស្សុទនរកប្រាំបីម៉ឺនឆ្នាំ , លុះរួចដោះអំពីឧស្សុទនរកនោះក៏បានទៅកើតក្នុងស្ថានត្រៃត្រិង្ស, លុះអស់អាយុអំពីស្ថាន

ត្រៃត្រិង្ស ព្រះឥន្ទ្រាធិរាជក៏ទៅនិមន្តពោធិសត្វ មិននិមន្តតែពោធិសត្វនោះឡើយ និមន្តទេវបុត្រដទៃ ៥០០ ទៀត ទើបព្រះអង្គទទួលនិមន្តព្រះឥន្ទ្រធ្វើវិមុត្តិច្យុតស្រុត ចុះមកចាប់បដិសន្ធិព្រមមួយអន្លើ និងទេវបុត្រទាំង ៥០០ ព្រះបរមពោធិសត្វទៅចាប់បដិសន្ធិក្នុងផ្ទៃនាងឆន្ទាទេវី ទេវបុត្រទាំង ៥០០ ក៏បដិសន្ធិក្នុងផ្ទៃប្រពន្ធអមាត្យទាំង ៥០០ នាងឆន្ទាទេវី នាងទ្រង់គភ៌ពោធិសត្វ បានខែ ១០ គ្រប់បរិបូណ៌ហើយ នាងក៏ប្រសូតព្រះរាជបុត្រចេញមក ។ លុះព្រះមហាក្សត្រាធិរាជ ជ្រាបថានាងប្រសូតព្រះរាជបុត្រដូច្នោះហើយ ស្ដេចឲ្យរើសរកមេនំបំបៅព្រះពោធិសត្វនោះ ឲ្យបាន ៦០។, ឯកូនអមាត្យទាំង ៥០០ ក៏ស្ដេចឲ្យនាំមកធ្វើជាបរិវារពោធិសត្វ ហើយព្រះមហាក្សត្រមានព្រះបន្ទូលនឹងនាងឆន្ទាទេវីថា : ឆន្ទេ ម្នាលនាងឆន្ទាទេវី ស្វេតច្ឆត្រអញនេះអញប្រគល់ឲ្យកូននាង មានព្រះបន្ទូលតែប៉ុណ្ណោះ

សោតមហាក្សត្រឲ្យហៅព្រាហ្មណ៍ហោរ មកទាយលក្ខណៈ
ពោធិសត្វទីឯសន្មតនាមឈ្មោះ, ព្រាហ្មណា តំ សុ-
ត្វា ព្រាហ្មណ៍ទាំងឡាយបានស្តាប់ព្រះឱង្ការមហាក្សត្រ ក៏
លើកករយ៉ាក់លើសិរសា អាត្មាភាពបន្ទាបកាយថ្វាយបង្គំទូល
ថា ទេវ បពិត្រក្សត្រថ្លៃប្រសើរអើយ ព្រះរាជបុត្រព្រះ
អង្គនេះសន្មតហៅថា " តេមិយ " ដ្បិតព្រះរាជបុត្រ
កាលប្រសូតចេញអំពីគភ៌មាតា មហាមេឃបង្អុរនូវភ្លៀង
នោះមហិមាក្រៃ , បពិត្រអើយ ! គ្រានោះពោធិសត្វចំរើន
ព្រះជន្មបានខែ ១០ មេនំក៏នាំពោធិសត្វ ទៅកាន់សំណាក់
ព្រះវររាជបិតា ។ តទា កាលនោះមានអមាត្យមួយ នាំ
យកចោរបួននាក់ ព្រះបិតាក៏ឲ្យធ្វើតាមអាជ្ញាស្តេច ។ ពោ-
ធិសត្តោ តំ ទិស្វា ព្រះបរមពោធិសត្វ បានឃើញ
នូវចោរនោះ ក៏មកគិតពិចារណាថា បិតាអញនេះអ្នកលុះ
នូវកម្មដ៏ប្រេះ ហេតុតែអាស្រ័យនូវរាជសម្បត្តិ , ឲអញអើយ

ធ្វើម្តេចនឹងបានរូបអំពីកជសម្បត្តិ កាលនោះមានទេវតាមួយឈ្មោះនាងទេពធីតា ជាមាតាពោធិសត្វអំពីមុន នាងយល់ពោធិសត្វជាទុក្ខដូច្នោះហើយ ទើបនាងស្រដីទៅកាន់ពោធិសត្វថា គេមិយកកុមារ នៃគេមិយកុមារអើយ ថាបើអ្នកនឹងចង់រូបអំពីកជសម្បត្តិនេះ ថាបើមិនគក៏ធ្វើជាគ ថាបើមិនថ្លង់ក៏ធ្វើជាថ្លង់ , រីឯពោធិសត្វសោតក៏ធ្វើជាគជាថ្លង់ តាំងតែអំពីថ្ងៃនោះមក ៗ រីអស់មេទំផងទាំងឡាយ យកសេចក្តីក្រាបទូលដល់ព្រះវរពជបិតា ទើបព្រះមហាក្សត្រញ៉ាំងអមាត្យឲ្យល្បងព្រះបរមពោធិសត្វ - គឺល្បងបង្អត់បាយ ១ បង្អត់ទឹកដោះ ១ ល្បងនូវចំណី ១ ល្បងនូវផ្លែឈើ ១ ល្បងនូវដំរីសេះរទេះគោក្របី ១ ល្បងនូវភ្លើង ១ ល្បងនូវពស់ ១ ល្បងនូវមហាស្រព ១ ល្បងនូវដាវ ១ ល្បងនូវស្គរតិរ- ១ ល្បងនូវប្រទីប ១ ល្បងនូវរុយ ១ ល្បងនូវលាមក ១ , ល្បងនូវកំដៅភ្លើង ១ ល្បងនឹងរូបស្រី ១ ដែលមហាក្សត្រ

ឲ្យល្បងពោធិសត្វនោះ មិនមែនតែ មួយខែ ឬ ២ ខែ ឡើយ ដល់អស់ ១ ឆ្នាំ ទើបព្រះពោធិសត្វយកទសុខ្ទនរកមក ពិចារណាពុំអាចនឹងរន្ធត់ញាប់ញ័រឡើយ ទើបមហាក្សត្រឲ្យ ហៅព្រាហ្មណ៍ហោរាមក ទើបព្រាហ្មណ៍ទាំងឡាយ ក្រាប ទូលមហាក្សត្រថា ទេវ បពិត្រក្សត្រថ្លៃប្រសើរអើយ យើង ខ្ញុំឃើញច្បាស់ជាព្រះរាជបុត្រជាអពមង្គល ថាបើខ្ញុំនឹង ទាយថារាជបុត្រជាអពមង្គល សមមហាក្សត្រមិនសប្បាយព្រះ ទ័យ ហេតុនោះបានជាខ្ញុំទាយថាជាមង្គលល្អ ទើបមហា ក្សត្រឲ្យនាយសារថីយកព្រះរាជបុត្រដាក់ក្នុងរទេះ នឹងនាំពោធិ សត្វទៅសម្លាប់ ទើបនាង ចន្ទាទេវី ក៏សូមឲ្យពោធិសត្វ សោយរាជបាន ៧ ថ្ងៃស្រេចហើយ សុនន្ទសារថីបររាជរថ ចេញអំពីព្រះនគរបាន ៣០០ យោជន៍ដល់ដងព្រៃធំ ហើយ ជីករណ្តៅទៅទាហានមួយ ៗ តទទន្តុំ លំដាប់នោះ ព្រះបរមពោធិសត្វទ្រង់ពិចារណាថា រីសុនន្ទសារថីរក់នឹងចាប់

អញសម្លាប់ក្តី អញក៏នឹងប្រយុទ្ធនឹងសុនន្ទសារថីនេះឯង ហើយ
ព្រះអង្គដើរទៅទៀបកន្ទៀរទេភជរថ ក្សណានោះមិនយូរឡើយ
ក៏គេក្រើកទៅដល់អាសនាសម្តេចអម្រិន្ទឥន្ទ្រាធិរាជ ប្រើវិស្ស-
កម្មទេវបុត្រឲ្យយកគ្រឿងទៅបំពាក់ពោធិសត្វ ទើបពោធិសត្វ
យាងទៅស្ថិតទៀបមាត់រណ្តៅ ហើយមានព្រះបន្ទូលថា នៃ
នាយសារថីអើយអ្នកជីករណ្តៅធ្វើនេះតើមានហេតុអ្វី ? នាយ
សារថីយល់ព្រះពោធិសត្វជាអស្ចារ្យក្រៃក្រ ក៏យកសេចក្តីក្រាប
ទូលព្រះវររាជបិតា ៗ តរោ ព្ធំគ្រានោះសម្តេចអម្រិន្ទ
ឥន្ទ្រកោសិយ ក៏ប្រើវិស្សកម្មទេវបុត្រឲ្យមកនិម្មិតជាសាលាពីរ
សាលា១សម្រាប់ក្រសាលយប់, សាលា១សម្រាប់ក្រសាល
ថ្ងៃ ហើយនិម្មិតជាគ្រឿងបរិក្ខារសម្រាប់អ្នកបួស ហើយ
សរសេរសំបុត្រមួយថា បើបុរសបុគ្គលណាមួយ ចង់បួស
ចូរយកគ្រឿងបរិក្ខារនេះចុះ ៗ បពិត្រតើយ គ្រានោះព្រះ

បរមពោធិសត្វ យកសំពត់សម្បកឈើធ្វើជាគ្រឿងបរិក្ខារ យកស្បែកខ្លាឃ្មុំទាំងក្រចកជាទ្រព្យប្រពៃ ហើយស្តេចចំរើននូវព្រហ្មវិហារទាំងបួន, នឹងអភិញ្ញាប្រាំមួយ, សមាបត្តិប្រាំបី ហើយទៅស្ថិតនៅទីចង្ក្រមណ៍ ព្រះវររាជបិតាក៏នាំពួកសេនា ១ម៉ឺន ២ពាន់ ៤រយ ៩៦ ចូលទៅបួសក្នុងសំណាក់ព្រះបរមពោធិសត្វ, គ្រានោះមានស្តេចមួយព្រះអង្គទ្រង់ព្រះនាមសមុទ្ទរាជ ចូលទៅបួសក្នុងសំណាក់ព្រះបរមពោធិសត្វដែរ, បពិត្រតើយើងអស់មហាជនឥសីផងទាំងឡាយសឹងបង្កើតអភិញ្ញាឈានសមាបត្តិទាំង ៨ លុះអស់អាយុក៏ទៅកើតក្នុងព្រហ្មលោកឆាយហោង ។ ឯនាងទេពធីតាបានមកជាឧប-លវណ្ណា ឯសុទន្តសារថីបានជាព្រះសារីបុត្តត្ថេរ ឯព្រះឥន្ទ្របានមកជាព្រះអនុរុទ្ធត្ថេរ ឯនាងឆន្នាទេវីបានមកជាព្រះក-ខ្មាង ឯព្រះរាជបិតាបានមកជាព្រះបាទសិរីសុទ្ធោទនមហារាជ ឯបរិស័ទបានមកជាបរិស័ទ ។ ឯនឹងសរសើរដំណើរ·

តំណាលកាលព្រះអគ្គិយកកំណើតកើតជា  តេមិយកុមារនេះ
មិញជាតំរប់ ១ ជាតិ  ជាស្ងួរេចហើយ ៗ

+

+ +

# ២_ មហាជនកជាតក

គ្រានេះ នឹងសំដែងក្នុងមហាជនកជាតក ក្នុងជាតកជាគំរប់ ២ ជាតំណោតសេចក្ដីទៅទៀត ។

អតីតេ វិទេហរដ្ឋេ មិថិលាយំ មហាជនកោ ញាម រាជា រជ្ជំ ការេសិ ក្នុងកាលនោះកន្លងរំលងយូរយារណាស់ទៅហើយ មានក្សត្រាធិរាជមួយព្រះអង្គ ទ្រង់ព្រះនាមមហាជនកសោយរាជ្យសម្បត្តិ នៅនាមិថិលានគរ ក្នុងដែនវិទេហរាស ព្រះមហាក្សត្រនោះមានព្រះរាជបុត្រពីរព្រះអង្គ ព្រះរាជបុត្រច្បងនោះឈ្មោះអរិ-ដ្ឋជនក ព្រះរាជបុត្រជាប្អូនឈ្មោះព្រះ បោលជនក ។ ព្រះបាទអរិដ្ឋជនក កាលដែលព្រះវររាជបិតាគង់ព្រះជន្មនៅឡើយនោះ ជាស្ដេចមហាឧបរាជ លុះផុតអំពីបិតាទៅកាលណាក៏បានសេពសោយរាជសម្បត្តិ ។ លុះជា ក្នុងគ្រានោះមាន

អមាត្យមួយចូលទៅញុះញង់មហាក្សត្រថា : ទេវ បពិត្រក្សត្រថ្លៃប្រសើរអើយ  សម្ដេចព្រះអនុជឥឡូវនេះនឹងចង់ដណ្ដើមយកស្វេតច្ឆត្រនៃព្រះអង្គហើយ  ព្រះរាជាបានស្ដាប់ពាក្យអមាត្យទូលព្រះអង្គដូច្នោះហើយ  ព្រះអង្គគង់ស្ងៀម ហេតុព្រះអង្គស្រឡាញ់សម្ដេចព្រះអនុជក្រៃពេកណាស់ លុះអមាត្យទូលជាគំរប់ ២ដង ៣ដង  ព្រះមហាក្សត្រក៏ក្រេវក្រោធពិរោធក្រៃ ក៏ប្រើអមាត្យឲ្យទៅចាប់យកបោលជនកមកដាក់ ច្រួលច្រវាក់ទៀបព្រះរាជវាំង, រីឯព្រះបាទបោលជនកក៏មកគិតពិចារណាថា  អញមានទោសអ្វីនឹងអ្នកជាបង  បានជាអ្នកបងធ្វើទោសជាទម្ងន់ក្រៃពេកម្ល៉េះ, ស្ដេចរំពឹងរកទោសនៃអាត្មាឥតអ្គឹមាន ហើយស្ដេចក៏តាំងអធិដ្ឋានថា : ទេវតា  បពិត្រទេវតាផងទាំងឡាយអើយ  ថាបើខ្ញុំមានចិត្តកំណាចនឹងអ្នកជាបង  រីឯឃ្នាងឃ្នោះច្រួលច្រវាក់នេះកុំបីឲ្យរដោះចេញ  ថាបើខ្ញុំមានចិត្ត

ស្លុតត្រង់ទឹងអ្នកជាបង់ទេ រីឃ្នាងនោះប្រួលប្រវាក់ឲ្យរង្គោះ
របូតចេញ ព្រះបាទបោលជនកអធិដ្ឋានដូច្នោះកាល
ឯណា រីឃ្នាងនោះប្រួលប្រវាក់ ក៏របូតរង្គោះចេញ
ហើយរត់ចេញ ទៅនៅចុងស្រុក ហើយសម្តេចព្រះ
អនុជ ក៏រៀបជាគ្រឿងទ័ពចូលទៅក្នុងនគរមិថិលា អមាត្យ
ទាំងឡាយក៏យកសេចក្តីក្រាបទូលដល់ព្រះចក្រី ទើប
ស្តេចរៀបពលសកលយោធាស្រេចហើយ ស្តេចក៏ហៅទេពី
មកផ្តាំថា ៖ ទេវី ហៃនាងអើយ គភ៌នាងចាស់បរិបូណ៌ហើយ
ឥឡូវនេះបងចូលច្បាំងក្នុងសង្គ្រាម ថាបើបងក្ស័យជីវិតទៅ
ប្អូននាងនៅស្រុកឯណាគួរនឹងរក្សាគភ៌នាងបាន ប្អូននាងចូល
ទៅនៅនាក្នុងស្រុកនោះ សម្តេចព្រះចក្រីផ្តាំអគ្គមហេសីស្រេច
កាលណាហើយ ស្តេចយាងចូលទៅកាន់សង្គ្រាម រីឯអស់
ពួកពលព្រះបាទបោលជនក ក៏ចាក់ព្រះបាទអរិដ្ឋជនកធ្លាក់
មកអំពីកដំរី ឲ្យក្សិណក្ស័យក្នុងគ្រានោះ រីឯនាងទេវីលុះឮ

ជាព្រះកមជាស្វាមីក្សីណក្ស័យជីវិតហើយ នាងក៏ជ្រើសរើស
រកទ្រព្យដែលមានខ្លឹមសារ ដាក់ក្នុងកញ្ចើកន្ទៀតដើរចេញ
ទៅកាន់ចម្បាកនគរ ហេតុតែពុំដឹងផ្លូវ នាងក៏វង្វេងទៅដល់
សាលាមួយ , នាងក៏ឈប់ចតលើសាលានោះ ៗ តស្សា
តេជេន សក្កស្ស កវ់ធំ ឧណ្ហាការំ ទស្សេ-
សិ បពិត្រតើយហេតុតែផលតេជះ ព្រះបរមពោធិសត្វ មក
តាប់បដិសន្ធិ ក្នុងគភ៌នាងនោះ កក្រើកទៅដល់អាសនាព្រះ
ឥន្ទ្រ ក្តៅក្រហាយសម្តេ អម្រិន្ទ្រឥន្ទ្រកោសីយ៍ក៏រមិលមើលដោយ
នូវព្រះនេត្រមួយពាន់ ឃើញនាងទេវី មា ប្រាថ្នាដើម្បីនឹង
បង់ទៅចម្បាកនគរ ព្រះឥន្ទ្រក៏និម្មិត ធ្វើជាតាចាស់ នាំនាង
ដោយកដរថទៅកាន់ចម្បាកនគរ ដល់សាលាមួយទៀតចម្បាក
នគរនោះ ដំកល់ទុកនាងលើសាលានោះ ហើយសម្តេច
អម្រិន្ទ្រឥន្ទ្រកោសីយ៍ ក៏លានាងហោះទៅកាន់ប្រាសាទវិញ ៗ
បពិត្រអើយហេតុតែតេជះ ព្រះបរមពោធិសត្វស្ថិត នៅក្នុងឧទរ

នៃនាង វីអាចារ្យទិសាបាមោក្ខ ដ៏ជាធំក្នុងបម្រាកនគរ ក៏
កើតអផ្សុក, ក៏នាំកូនសិស្សទាំង ៥០០ ចេញទៅកាន់សា-
លាដែលជីតានាងនៅ ។ ធិស្សាចាមោក្ខោ តាំ ធិ-
ស្សា រីឯអាចារ្យទិសាបាមោក្ខ បានឃើញនូវនាងជីតា
ហេតុតែព្រះប៉ារមីពោធិសត្វស្ថិតនៅក្នុងទ្វារនៃនាងនោះ ក៏
បង្កើតសេចក្ដីស្រឡាញ់ហាក់ប៉ីដូចជាប្អូនស្រីបង្កើត ហើយ
ក៏ជណ្ដឹង: កកធិ តាំ តាមំ វសិ ម្នាលប្អូនស្រី!
ដំណើរ ដែលព្រាត់ប្រាសចេញអំពីនគរប្រការ ១ ដែលតា
ចាស់នាំមកដាក់លើសាលានេះប្រការ ១ ។ អាចារ្យទិសា-
បាមោក្ខ បានស្ដាប់ពាក្យជីតានាងរៀបរាប់ ប្រាប់តាមដំណើរ,
អាចារ្យទិសាបាមោក្ខ ក៏អាសូរករុណានៃនាងមហិមា ហើយ
ប្រើកូនសិស្ស ទាំងប្រាំរយ ឲ្យនាំយកនូវរទេះហើយអញ្ជើញ
ជីតាឲ្យទៅព្រមល្មមនឹងអាត្មា ក្នុងគ្រាកាលនោះហោង
ចាប់ដើមតាំងតែអំពីថ្ងៃនោះមក អាចារ្យទិសាបាមោក្ខ ក៏

បញ្ចឹមរក្សាជាប្រក្រតីពុំដែលដាច់ឡើយ ។ សាធ ចិរ-ស្សេវ សុវណ្ណវណ្ណោ បុត្តំ វិជាយិ មហា-ជនកកុមារកេតិស្ស អយ្យ កស្ស សន្តិ-កាំ ជាមំ អាកាសិ ។ នាងទេវីនោះទ្រង់គភ៌ពោធិ-សត្វបានខែ ១០ គ្រប់បរិបូណ៌ពុំយូរឡើយ នាងក៏ប្រសូតពោ-ធិសត្វ ដ៏មានព្រះរូបឆោមឆោះល្អ មានសម្បុរដូចមាសជាទី ស្រឡាញ់ពេញចិត្តអ្នកផងទាំងឡាយ អាចារ្យទិសាបាមោក្ខ ក៏សន្មតឈ្មោះពោធិសត្វហៅថាព្រះមហាជនកកុមារ ។ សោ វឌ្ឍមានោ ទារកេហិ សទ្ធឹ កីឡន្តោ យេវ ឆ ការកេ សន្តិ ពោធិសត្វមហាបុរសគន់ លុះព្រះអង្គចំរើន ធំឡើងទៅលេងជាមួយក្មេងទាំងឡាយទាំងប្អូន ហើយក៏វាយ អស់ក្មេងទាំងប្អូន ឯក្មេងទាំងប្អូនក៏រត់ទៅកាន់ផ្ទះមាតាបិតា រីឯមាតាបិតានៃក្មេងផងទាំងឡាយក៏ត្មះតិះដៀលពោធិសត្វថា: នៃ ! កូនឥតបានេះសាហាវក្រៃពេកណាស់ ម្តេចក៏វាយកូន

អញ ? ពោធិសត្វបានឮគេត្មះតិះដៀលដូច្នោះហើយក៏ដណ្តឹង
ទៅមាតាថា ៖ អម្ពះ បពិត្រអ្នកមេដ៏មានគុណខ្ញុំអើយ ចូរ
អ្នកបង្ហាញនូវបិតាខ្ញុំ បើអ្នកពុំបានប្រាប់ខ្ញុំទេ ខ្ញុំនឹងខាំដោះ
នៃអ្នកក្នុងកាលឥឡូវនេះ ; រីឯមាតាក៏ពុំអាចដើម្បីនឹងបញ្ឆោត
ព្រះរាជបុត្របានឡើយ នាងក៏ទ្រង់ព្រះកន្សែងទួញថា :
តាត ៖ ម្នាលកូនសួនសំឡាញ់មាសម្ដាយអើយ ឯបិតានៃ
អ្នកនោះក្សិណក្ស័យទៅហើយ នាងរៀបរាប់ប្រាប់សព្វគ្រប់
ប្រការ ; ទើបព្រះពោធិសត្វចំរើនព្រះជន្មបាន ១៦ ឆ្នាំក៏បាន
រៀនចប់ត្រៃវេទទាំងបីគ្មានសល់ ; ហេតុតែប្រាជ្ញាបារមីហើយ
ពោធិសត្វនឹងចង់ទៅយកស្វេតច្ឆត្រនគរមិថិលា ក៏សូមយកកែវ
មុក្តាហារកែវមុនីកែវវជីររត្នអំពីមាតាព្រះពោធិសត្វ ទៅមួយ
អន្លើដោយឈ្មួញសំពៅ ៗ បពិត្រអើយថ្ងៃដែលពោធិសត្វ
ឡើងលើសំពៅ រីឯព្រះបាទបោលជនកក៏អាពាធជាទម្ងន់ក្នុង
ថ្ងៃនោះ នាយសំពៅទាំងប្រាំពីររយ ក៏បើកសំពៅចេញទៅ

បាន ៧ ថ្ងៃ សំពៅក៏បែកធ្លាយកណ្ដាលសមុទ្រ រីអស់អ្នកសំពៅប៉ុន្មានគ្មានសល់ ពោធិសត្វសោតក៏ឡើងផងក្ដាង លោតរំលងទៅអស់ថ្នាមមករផងទាំងឡាយមានចម្ងាយ១១សក, ថ្ងៃដែលព្រះពោធិសត្វធ្លាក់ក្នុងសមុទ្រ ព្រះបាទបោលជនកក៏ទ្រង់សោយព្រះវិលាល័យក្ស័យព្រះជន្មាទៅក្នុងថ្ងៃនោះ ពោធិសត្វនោះសោត នាងមណីមេខលាក៏នាំទៅដាក់លើថ្មជាមង្គលក្រោមដើមស្វាយ ហើយនាងយកពីតាមួយឲ្យរក្សាពោធិសត្វនៅទីនោះ ឯព្រះបាទបោលជនកកាលដែលព្រះអង្គសោយព្រះវិលាល័យក្ស័យព្រះជន្មទៅ មានតែព្រះរាជបុត្រី ឯព្រះរាជបុត្រាព្រះអង្គនោះគ្មានទេ អស់សេនាមន្ត្រីផងទាំងឡាយ មានព្រាហ្មណ៍បុរោហិតជាដើមក៏នាំយកនូវបុស្សរថនោះមក ហើយថ្វាយបង្គំអធិដ្ឋានថា បពិត្របុស្សរថប្រសើរអើយ រីអស់យើងខ្ញុំផងទាំងឡាយ មានប្រាថ្នាចង់បានមហាក្សត្រាធិរាជមកសោយរាជ្យក្នុងនគរមិថិលានេះ សុំបុស្ស

ថៃបានព្រមហាជនអធិដ្ឋានផ្សងដូច្នោះហើយ បុស្សរថក៏យា-
ត្រា មានមុខឆ្ពោះទៅកាន់ឧទ្យានដែលព្រះអង្គស្ថិតនៅក្នុងទី
នោះទើបអស់មហាជនក៏អញ្ជើញព្រះអង្គមកសោយរាជសម្បត្តិ
ព្រមមួយអន្លើដោយព្រះរាជបុត្រីនៃព្រះមហាក្សត្រក្នុងនគរមិថិ
លា ហើយព្រះអង្គលើកធ្នូមានកម្លាំងមួយពាន់បុរសផុសសឹង
កំណាប់ ១៦ ស្រេចកាលឯណា ព្រះរាជាបន្ទូលបង្គាប់ប្រើអ-
មាត្យផងទាំងឡាយឲ្យសង់សាលាបាន ៦ ហើយមហាក្សត្រ
ឲ្យទ្រព្យជាទានដល់ស្មូមយាចកផងទាំងឡាយ ព្រះមហាក្សត្រ
សោយរាជសម្បត្តិដោយទសពិធរាជធម៌ទាំង ១០ ប្រការ រក្សា
អស់ទាំងអាណាប្រជាជនក្នុងផ្ទៃក្រោម លុះយូរបន្តិចទៅ រ-
នាងសិម្ពលីទេពីមិញ នាងក៏ប្រសូតរាជបុត្រប្រុស ១ សន្មត
នាមហៅថា ចៅទីឃាវុកុមារ លុះទីឃាវុកុមារចំរើនធំឡើង
មហាក្សត្រាធិរាជដំកល់ព្រះរាជបុត្រនោះជាឧបរាជ ។ ឯកា-
ស្មឹ សមយេ បពិត្រអើយ មានកាលសម័យថ្ងៃមួយ រាជា

វព្រះមហាក្សត្រាធិកដក៏នាំអស់បរិពារ ទៅលេងសួនស្វាយ ហើយពោធិសត្វក៏ពិចារណានូវស្វាយដែលនឹងមិនមានផ្លែនោះ ក៏កាត់បង់នូវបុត្រ ភរិយា និងកេដសម្បត្តិ ឥតមានសង្ស័យ អាល័យឡើយ ហើយចេញទៅសាងព្រះផ្នួស ៗ បពិត្រ អើយដូចយើងបាននិទានមក កាលនោះអាយុមនុស្សផងទាំងឡាយមួយម៉ឺនឆ្នាំ ពោធិសត្វសោយរាជសម្បត្តិនោះ ព្រះជន្មបាន ៧ ពាន់ឆ្នាំ កាលព្រះអង្គទ្រង់ព្រះផ្នួស ព្រះជន្មបាន ៣ ពាន់ឆ្នាំ ព្រះអង្គយាងចូលទៅក្នុងហិមពាន្ត ទើបពពួកសេនាផងទាំងឡាយ មានព្រះអគ្គមហេសីជាដើម ក៏តាមព្រះអង្គទៅ , ហេតុតែមានចិត្តអាល័យក្សត្រថ្លៃក្រពេកណាស់ នឹងចង់ឲ្យមហាក្សត្រ ត្រឡប់វិលមកព្រះនគរវិញ ហើយគក់ទ្រង់ធ្លួញយំ ផាលផ្ទោក ទឹកព្រះនេត្រាក៏ហូរស្រក់ស្រាក់ ៗ តគា ក្នុងគ្រានោះ ឧរោភា តាបសោ មានតាបសពីរអង្គពិនិត្យពិចារណាថា : វព្រះមហាក្សត្រ

នេះ លុះទៅអនាគតម៉ិញនឹងបានត្រាស់ជាព្រះពុទ្ធប្រាកដ
មិនខានឡើយ បើដូច្នោះគួរអញនឹងទៅឲ្យពត៌មាន , តា-
បសគិតដូច្នោះហើយកាលឯណា ក៏ហោះទៅស្ថិតកណ្ដាល
អាកាស ឲ្យពត៌មានពោធិសត្វស្រេចហើយ ក៏ហោះមក
កាន់ស្ថានលំនៅនៃអាត្មាវិញ ៗ បពិត្រអើយ ឮដ៏កាល
នោះ ព្រះពោធិសត្វឲ្យដំបូន្មាននៃនាងសិម្ពលីទេវីគ្រប់ប្រ-
ការ ៗ សា សិម្ពលិទេវី នាងសិម្ពលីទេវីនោះ
នាងក៏បានស្ដាប់ដំបូន្មានពោធិសត្វដូច្នោះហើយ ហេតុតែស្ត្រី
នាង នឹងកាត់ អាល័យមិនបានឡើយ ហើយនាងក៏ប្រះ
ប្រាណខ្ទួញថា ឱ ! មហាជនកអើយ ចាប់ដើមតាំងតែ
អំពីថ្ងៃនេះទៅ កាលឯណា អ្នកនឹងនៅមួយអន្ទើនឹងអញ
នោះឥតអង្គមានឡើយ ហើយទេវីមាងក៏ទ្រង់កន្ទ្យង់អាណិត
អនាថ លើកព្រះហស្តទាំងពីរគរគក់ទ្រូង សន្ទប់នៅឮដ៏ផ្ទៃ
នោះ ទើបព្រះអគ្គជាប់ជា នាងសិម្ពលីដួលសន្ទប់ដូច្នោះហើយ

ព្រះអង្គក៏លុបនូវស្នាម ព្រះបាទាស្រេចហើយ ក៏យាង ចូលទៅក្នុងព្រៃ វីឯនាងទេវីលុះដឹងស្មារតីឡើង កាលឯណា រកស្នាមព្រះបាទា ព្រ៎ អង្គពុំឃើញឡើយ ហើយនាងគក់ ទ្រូងទួញយំជាលដំព្រះទុក ទឹកនេត្រាក៏ហូរស្រក់សស្រាក់ ធីតានាងប្រើអមាត្យផងទាំងឡាយ ឲ្យរត់រកពោធិសត្វ អ- មាត្យរកពុំឃើញឡើយ ទេវីនាងក៏ញាំងជនឲ្យសាងទូវចេតិយ៍ គ្រប់ទីដែលព្រះអង្គបន្ទូលនឹងនាងស្រេចហើយ នាងក៏អភិ- សេកពជបុត្រឲ្យសោយរាជសម្បត្តិ ក្នុងនគរមិថិលា ហើយ នាងក៏ចេញទៅបួស ជាមហាឫសីក្នុងព្រៃស្វាយ បង្កើត កសិណ វិបស្សនាឈានប្រសើរ ៗ កាលំ កាត្វា ធ្វើមរណកាលទៅ កាលឯណាក៏បានទៅកើតក្នុងព្រហ្មលោក ព្រះមហាក្សត្រក៏បានទៅកើតក្នុងព្រហ្មលោក , វីឯព្រះឥន្ទ្រ ចេវិលវិញមកបានជាព្រះអនុរុទ្ធ វីនាងទេពធីតាបានមកជានាង ទបល្ហូវណ្ណា វីតាបសទាំងពីរ តាបស ១ បានជាសា-

ឯបុត្តត្ថេរ តាបស ១ បានជាមហាមោគ្គល្លានត្ថេរ ឯនាងកុមារីបានជានាងខេមា ឯជាងវឌ្ឍកម្មបានជាព្រះអនន្ទត្ថេរ ឯនាងសិម្ពលីទេវី បានជានាងពិម្ពា ឯចៅទីឃាវុកុមារ បានជាពហុល ឯសម្តេចព្រះវរបិតា មាតា ពោធិសត្វនោះបានមកជាត្រកូលស្តេចធំ មហាជនកនរិន្ទ គឺអញតថាគតៗ

មហាជនក ជាតកំ និដ្ឋិតំ ឯនឹងពណ៌នាសរសើរដំណើរព្រះមហាជនក ជាគំរប់ពីរជាតិមិញ ជាសូរេចតែប៉ុណ្ណោះ ។

×

× ×

# ៣_ សុវណ្ណសាមជាតក

គ្រានេះ នឹងសំដែងកថ្ងជាតកជាគំរប់បីជាគំណត់សេចក្ដីតទៅទៀត អតីតេ ភិក្ខវេ ពារាណសិយំ ឧ តរតោ អវិទូរេ នទិយា ឱរមតីរេ ឯកោ នេសាទគាមោ អហោសិ បរតីរេ ច ឯកោ នេសាទគាមោ អហោសិ ឯកស្មឹ គាមេ បញ្ចបញ្ចកសតានិ វសន្តិ ទ្វេសុ គាមេសុ ទ្វេ នេសាទជេដ្ឋកា សហាយកា អហេសុំ ។ តេ ទហរកាលេយេវ ឯវំ កតិកំ ករឹសុ ឯកស្ស ធីតា ហោតិ ឯកស្ស បុត្តោ ហោតិ តេសុ មយំ វិវាហំ កច្ឆាមាតិ, ភិក្ខវេ ម្នាលភិក្ខុទាំងឡាយអើយព្រេងកប្បខាំងកំបាំងកន្លងរំលងទៅយូរហើយ មាននាយនេសាទពីរនាក់ នៅនាស្រុកមួយមិន

ឆ្ងាយអំពីនគរពារាណសី ម្នាក់នៅនាត្រើយនាយស្ទឹង ម្នាក់ទៀតនៅនាត្រើយអាយស្ទឹង ៗ នេសាទទាំងពីរនោះ នេសាទម្នាក់ៗ មានបរិវារ៥០០ ៗ ៗ នេសាទទាំងពីរជាសំឡាញ់នឹងគ្នា កាលនៅពីក្មេងតែងលេងជាមួយគ្នា, មានកាលថ្ងៃមួយនោះ នេសាទទាំងពីរបានប្តេជ្ញានឹងគ្នាថា : សម្ល ហៃសំឡាញ់អើយ បើយើងទាំងពីរបំរើនធំឡើង ហើយសំឡាញ់មានកូនប្រុសក្តី យើងមានកូនស្រីក្តី យើងនឹងផ្សំផ្គុំគ្នាឲ្យជាប្តីប្រពន្ធកុំឲ្យដាច់សំឡាញ់នឹងគ្នា លុះយូរបន្តិចទៅ នេសាទត្រើយអាយក៏ប្រសូតកូនប្រុស ទ្រង់នាមឈ្មោះទុកូលកុមារ ព្រោះមហាជនយកសំពត់ទុកូលក្រស្តមកទទួលកាលប្រសូត នេសាទត្រើយនាយក៏បានកូនស្រីមួយ សន្មតនាមឈ្មោះបារិកា, លុះដល់អាយុបាន ១៦ ឆ្នាំ មាតាបិតាក៏ផ្សំផ្គុំគ្នាជាប្តីប្រពន្ធ ជនទាំងពីរគឺទុកូលកុមារ និងនាងបារិកា ក៏

អង្វរមាតាបិតាថា : អម្ម តាត បពិត្រអ្នកម៉ែអ្នកឪខ្ញុំអើយ ខ្ញុំមិនអាចដើម្បីនឹងនៅជាឃរាវាសនោះឡើយ រីអ្នកទាំងពីរមិនបង់ដល់ប៉ុន្មានក្តី ក៏មាតាបិតាផ្សំនឹងគ្នាមក, ចាប់ដើមតាំងតែអំពីនោះ រីអ្នកទាំងពីរក៏ចេញទៅបួស ហេតុតែតេជះអ្នកទាំងពីរ ក៏កក្រើកដល់អាសនាព្រះឥន្ទ្រ ទើបព្រះឥន្ទ្រប្រើវិស្ស-កម្មទេវបុត្រឲ្យមកនិម្មិតជាបរមសាលា មានទាំងគ្រឿងបរិក្ខារសុទ្ធសឹងបរិសុទ្ធសម្រាប់អ្នកបួស ទុកក្នុងសាលានោះស្រេច កាលឯណោះ ឧភោ ជនា ជនទាំងពីរក៏ដើរមានមុខឆ្ពោះទៅកាន់ទីនោះ ។ តំ ទិស្វា ជនទាំងពីរឃើញនូវសាលានោះ មានទាំងគ្រឿងបរិក្ខារគ្រប់ប្រដាប់ គិតពិចារណាថា : សាលានេះគឺព្រះឥន្ទ្រនិម្មិតមានទាំងគ្រឿងបរិក្ខារ ជនទាំងពីរក៏ចូលទៅ យកនូវគ្រឿងបរិក្ខារនោះ ក៏បួសជាមហាឫសីនៅអាស្រ័យក្នុងសាលានោះ រីឯព្រះឥន្ទ្រសោតក៏ចូលទៅបំរើគា-

បសទាំងពីរតែសព្វថ្ងៃ ទើបព្រះឥន្ទ្រគិតពិចារណាទៅឃើញតាបសទាំងពីរមានភេទនឹងខ្វាក់ភ្នែក ព្រះឥន្ទ្រនិមន្តតាបសឲ្យសេពមេថុនធម្ម តាបសពុំព្រមទទួលសេពឡើយ ទើបព្រះឥន្ទ្រនិមន្តឲ្យស្ទាបអផ្ដែលទនេ តាបសក៏ព្រមទទួល លុះយូរបន្តិចទៅនាងទុក្ខបារិកាក៏មានគភ៌ គ្រប់ខែ១០ ហើយ ក៏ប្រសូតពោធិសត្វ សន្មតឈ្មោះហៅថាសុវណ្ណសាម តាំងតែអំពីថ្ងៃនោះមក ។

បពិត្រអើយ មានកាលសម័យថ្ងៃមួយ តាបសក៏ទៅរកបេះផ្លែឈើនូវមើមឈើ លុះថ្ងៃរសៀលទន់តាបបន្តិច អ្នកទាំងពីរក៏ត្រឡប់វិញ មក អំពីព្រៃដល់ស្ពានមួយ មិនឆ្ងាយអំពីបរមសាលានោះ កាលនោះមហាមេឃផ្តាលពពកបង្អុរនូវភ្លៀងនោះច្រើន អ្នកទាំងពីរក៏រត់ទៅជ្រកក្រោមម្លប់ឈើដែលដុះលើដំបូកមួយ , កាលនោះមានពស់វែកមួយនៅក្នុងដំបូកនោះក៏ព្រួសពិសត្រូវភ្នែកអ្នកទាំងពីរងងឹតសូន្យសុង និង

ស្រមឹលមើលគ្នាក៏ពុំយល់ឡើយ ម្ល៉ោះហើយអ្នកទាំងពីរទឹងទៅ
ទីណាក៏ពុំរួច ។ អថខោ ពោធិសត្តោ គ្រានោះ
ព្រះបរមពោធិសត្វ ទទឹងមាតាបិតាបាត់ដូច្នោះ ព្រះហត្ថា
កាន់យកនូវឈើច្រត់ចេញចាកអំពីបរមសាលា ។ ឥតោ
បដ្ឋាយ ចាប់ដើមតាំងតែអំពីថ្ងៃនោះក៏រកផ្លែឈើនឹងមើម
ឈើ ដងទឹកស្រង់ទឹកឆាន់មួយអន្លើនឹងហ្វូងសត្វអម្រឹគអម្រឹគា
ជាបរិវារចិញ្ចឹមមាតាបិតាតែសព្វថ្ងៃ ។ ឥតោ ឆាកណសំ-
យំ ឃៈតោ កាសិករាជា, គ្រានោះ មានស្តេច
កាសិករាជមួយព្រះអង្គទ្រង់ព្រះនាមព្រះបាទបិលយក្ស ប្រ-
គល់រាជសម្បត្តិឲ្យបិតាចេញទៅប្រពាតព្រៃ ដើម្បីនឹងសម្លាប់
នូវសត្វអម្រឹគ ឃើញពោធិសត្វដងទឹក មួយអន្លើនឹងសត្វអ-
ម្រឹគ ហើយក៏បាញ់នឹងព្រួញលាបថ្នាំពិសក៏ក្ស័យក្នុងទីនោះទើប
ធីតាឈ្មោះនាងសុន្ទរី ជាមាតានៃពោធិសត្វមកអំពីជាតិមុន

ស្រដីនឹងស្តេចយក្សថា : ម្នាលយក្សអើយ នាអ្នកសម្លាប់នេះ
មិនគឺស្លាប់តែមួយឡើយ ស្លាប់ជនដល់ពីរនាក់ យក្សបាន
ស្តាប់ទៅពីគាថាប្រាប់ដូច្នោះហើយ យក្សក៏ទៅកាន់សាលាប្រាប់
សព្វគ្រប់ប្រការដល់មាតាបិតា ហើយក៏នាំមាតានឹងបិតាមក
កាន់ពោធិសត្វ មាតានឹងបិតានឹងនាងសុន្ទរី អធិដ្ឋានដល់
ផល ដល់ពាក្យសច្ចៈ ដល់សីល-ទាន ដែលពោធិសត្វបាន
សាងសន្សំមកច្រើនជាតិ, ឯពិសពស់នោះក៏របូតធ្លាក់ចេញពី-
ភ្នែក មាតាបិតាក៏ភ្លឺឡើងក្នុងគ្រាដែលអធិដ្ឋាននោះ ពោធិសត្វ
រួចរស់ជីវិតឡើង ទ្រង់សំដែងទសធម៌ទាំង ១០ ប្រការដល់
ស្តេចយក្ស ហើយស្តេចយក្សក៏ត្រឡប់វិលទៅកាន់នគរហើយ
សោយរាជសម្បត្តិប្រកបដោយគន្ធងធម៌ លុះអស់ជីវិតទៅក៏
បានទៅកើតក្នុងឋានសួគ៌ទេវលោក ពោធិសត្វក៏ចំរើនឈាន
នឹងអភិញ្ញា មួយអន្លើនឹងមាតាបិតា លុះធ្វើមរណកាលទៅ
កាលឯណា ក៏បានទៅកើតក្នុងព្រហ្មលោក ឯព្រះបាទបិល-

យក្ស ក៏ចវិលវិញមកបានជាអនុទ្ធ រីចៅទុកុលកុមារបណ្ឌិត ចេរវិលវិញមកបានជាព្រះមហាកស្សបត្ថេរ, រីនាងទុបារិកាចេរ វិលវិញមកបានជាភទ្ទកាបិលានីភិក្ខុណី សុវណ្ណសាម ចេរ វិលវិញមកបានជាសម្តេចព្រះពុទ្ធអង្គ សុវណ្ណសាមជាត កំ និដ្ឋិតំ បពិត្រអើយយើងសរសើរដំណើរព្រះអង្គកាល យោនយកកំណើតកើតជាពោធិសត្វមួយព្រះអង្គ ទ្រង់ព្រះនាម ឈ្មោះសុវណ្ណសាមជាគំរប់ ៣ និដ្ឋិតំ ប្រេចនូវប្រការ អម្បាលនេះឯងហោង ។

+

\+ +

# ៤_ នេមិរាជជាតក

គ្រានេះ នឹងសំដែងក្នុងជាតកជាគំរប់ ៤ ជាដំណាត សេចក្តីទៅវិញទៀត គថា ភិក្ខុ គ្រានោះអស់ពពួកភិក្ខុផងទាំងឡាយ ក៏សរសើរដំណើរពីព្រះអង្គយ៉ាងអស្ចារ្យ ទើបសម្តេចព្រះបរមសាស្តាចារ្យ នាំអតីតនិទានមានពាក្យព្រះបាលីថា : អតីតេ ភិក្ខវេ វិទេហរដ្ឋេ មិថិលានគរេ មឃទេវោ នាម រជ្ជំ ការេសិ ។ ភិក្ខវេ ម្នាលភិក្ខុផងទាំងឡាយអើយ អតីតេ ក្នុងកាលកន្លងរំលងទៅយូរហើយ គ្រានោះមានមហាក្សត្រមួយព្រះអង្គ ទ្រង់ព្រះនាមព្រះបាទមឃទេវរាជ សោយរាជសម្បត្តិក្នុងនគរ មិថិលា ក្នុងកំឡុងស្រុកព្រះបាទវិទេហរាស្ត្រ ប្រកបដោយទសពិធរាជធម៌ ១០ ប្រការ លុះព្រះជន្មបាន ៤ ម៉ឺនឆ្នាំ បានជាមហាឧបរាជ លុះព្រះជន្មបាន ៨ ម៉ឺន

៤ ពាន់ឆ្នាំ ព្រះបិតា ក៏ទ្រង់ព្រះផ្នួស ព្រះមហាក្សត្រ ក៏បានប្រជុំនឹងខ្មាន់ព្រះកេសឲ្យមើលសក់ស្កូវ លុះឃើញហើយ ក៏បង់ចេញទ្រង់ព្រះផ្នួស ដូចព្រះវរបិតាដែរ ហើយក៏ចេញទៅទ្រង់ព្រះផ្នួសជាមហាឫសី កើតឡូវបញ្ញា អភិញ្ញា នឹងឈានអដ្ឋសមាបត្តិ នឹងព្រហ្មវិហារ ៤ មានព្រះជន្ម ៨ ម៉ឺន ៤ ពាន់ឆ្នាំ ទើបសោយទីវង្គតរលត់ខន្ធ បានទៅកើតក្នុងព្រហ្មលោក រីអស់ពពួកមហាក្សត្រ តាំង ៨ ម៉ឺន ៤ ពាន់ មានកជបុត្រជាដើម ក៏សឹងចេញទៅបួសដូចសេចក្តីបទដើមនោះហោង ។ លុះសោយព្រះទីវង្គតរលត់ខន្ធ ក៏បានទៅកើតក្នុងព្រហ្មលោកតាំងអស់ ទើបពោធិសត្វពិតពិលរមិលមើលឃើញថា នឹងសាបសូន្យព្រះញាតិវង្ស ព្រះអង្គក៏ធ្វើមុត្តិច្យុតស្រុតចុះមកចាប់បដិសន្ធិក្នុងទរអគ្គមហេសីនៃស្តេចមិថិលា លុះដល់ខែ ១០ ក៏ប្រសូតចេញចាកអំពីទរព្រះមាតា លុះចំរើនធំឡើង មាតា បិតា

សន្តតនាមឈ្មោះហៅនេមិរាជកុមារ ក៏មានចិត្តជ្រះថ្លា ក្នុងវរពុទ្ធសាសនា បានសង់សាលាទាន ៦ , បពិត្រអើយនាថ្ងៃ ១៥ ស្តេចនេមិរាជ មកមានសន្ទិះសង្ស័យទីងអានិសង្សទាំង ២ ប្រការ គឺសីល និងផ្នួសមិនដឹងជាឯណាមានផលច្រើន ព្រះឥន្ទ្រាធិរាជមកកាត់នូវសេចក្តីសន្ទិះសង្ស័យឃើញថាផលផ្នួសមានផលច្រើន ក៏នាំអតីតនិទាន មកសំដែងថ្វាយពោធិសត្វស្រេចកាលណា ក៏ហោះទៅកាន់ឋានតាវ-តឹង្សទេវលោក រីពួកទេវតាផងទាំងឡាយ ដណ្តឹងសម្តេចអម្រិន្ទកោសីយថា : ទេវរាជ បពិត្រស្តេចទេវតាអើយ អ្នកអញ្ជើញទៅទីឋានឯណា អម្បាញមិញយើងខ្ញុំ ក៏ពុំយល់ទើបព្រះឥន្ទ្រមានព្រះបន្ទូលថា : ទេវៈសង្ឃាយោ បពិត្រអស់ពួកទេវបុត្រទេវតាផងទាំងឡាយអើយ អញកាត់សេច-ក្តីសង្ស័យនៃស្តេចនេមិរាជ នៅឋានមនុស្សលោកនាយ ម្ល៉ោះ

ហើយអស់ពពួកទេវតាចង់ឃើញ ក៏ព្រះឥន្ទ្រប្រើវិស្សុកម្មឲ្យយកពេជ្រយន្តរថ ហោះចុះពាក់អំពីឋានទេវលោក មកអញ្ជើញពោធិសត្វទៅកាន់ឋានទេវលោក ។ ពោធិសត្តា ព្រះបរមពោធិសត្វឡើងគង់លើរថ ទើបមាតលីទេវបុត្រដណ្តឹងពោធិសត្វថា មហារាជ បពិត្រមហារាជអើយ មហារាជចង់យល់នរកមុន ឬចង់យល់សួគ៌ទេវលោកមុន ? ព្រះពោធិសត្វ ក៏ឆ្លើយថាចង់ឃើញនរកមុន ទើបមាតលីនាំពោធិសត្វទៅបង្ហាញនរកសព្វគ្រប់ កាលណា ក៏នាំទៅបង្ហាញសួគ៌ទេវលោក សម្តេចអម្រិន្ទ្រឥន្ទ្រាធិរាជ និមន្តឲ្យសោយរាជ្យពាក់កណ្តាល ពោធិសត្វពុំទទួលយករាជសម្បត្តិនោះឡើយ ហើយវិស្សុកម្មក៏នាំពោធិសត្វមកកាន់ឋានមនុស្សលោកវិញ លុះអំឡុងយូរបន្តិចទៅ មានព្រះរាជបុត្រ ១ ព្រះអង្គ លុះរាជបុត្រចំរើនធំឡើងកាលណា ពោធិសត្វក៏បង្វែររាជសម្បត្តិឲ្យទៅរាជបុត្រ ព្រះអង្គក៏ចេញទៅ សាង

ព្រះផុស្ស ពង់ព្រៃអម្ពវ័ន រីសម្តេចព្រះវរពជមាតាបិតា ក៏ចេរិលវិលមកបានជាពុទ្ធមាតាបិតា រីឯព្រះឥន្ទ្របានជាអនុរុទ្ធា-ចារ្យ ព្រះមាតុលី បានជាព្រះមហាអនន្ទ រីស្តេចទាំង ៨ ម៉ឺន ៤ ពាន់ បានជាពុទ្ធបរិស័ទព្រះបាទនេមិរាជបានមកជាព្រះតថាគតហ្នឹងឯង ៗ នេមិរាជជា- តកាំ និត្ថិតំ បពិត្រអើយ យើងពណ៌នាសរសើរតំណើរព្រះនេមិរាជជាតកនេះមិញ ចតុត្ថំ ជាគំរប់ ៤ ជាតិ និដ្ឋិតំ ក៏សូរវេចទូវប្រការទាំងអម្បាលនេះឯងហោង ៗ

×

× ×

# ៥_មហោសថជាតក

គ្រានេះ នឹងសម្តែងជាតកជាគំរប់ ៥ តទៅទៀត ឯកទា កាលេ ពុំគ្រានោះអស់ពួកភិក្ខុប្រជុំជុំគ្នា ក្នុងធម្មសភាសាលា សរសើរអំពីព្រះប្រាជ្ញា សម្តេចព្រះពុទ្ធអង្គ នឹងរកប្រាជ្ញាបុគ្គលឯណាប្រៀបធៀបមិនបាន ពាក្យនោះក៏រាមិនបាត់ស្ងាត់ ជ្រាបដល់ព្រះសោតទិព្វថ្វៃ ទើបសម្តេចព្រះពុទ្ធអង្គនាំនូវនិទានមានពារៈ ព្រះបាលីថា : អតីតេ ភិក្ខវេ ម្នាលភិក្ខុផងទាំងឡាយអើយ អតីតេ ក្នុងកាលកន្លងទៅហើយ គ្រានោះមានមហាក្សត្រមួយព្រះអង្គទ្រង់ព្រះនាមព្រះបាទវិទេហរាស្ត្រ សោយរាជសម្បត្តិដោយទសពិធរាជធម៌ទាំង ១០ ក្នុងមិថិលានគរ មានអ្នកប្រាជ្ញទាំង ៤ តែងទូន្មានប្រដៅ អាចារ្យទាំង ៤ នោះ គឺ អាចារ្យសេនក ១ , អាចារ្យបុក្កុស ១ , អាចារ្យទេវិន្ទ១

អាចារ្យកាមិន្ទ ១, អាចារ្យទាំង ៤ នេះ មានប្រាជ្ញាស្មើ ៗ គ្នា គ្រានោះព្រះមហាក្សត្រាធិរាជ ឃើញនូវសុបិននិមិត្ត ក៏មានបន្ទូលហៅអាចារ្យទាំង ៤ ឲ្យទាយទំនាយនិមិត្តនោះ ឃើញថានឹងបានអ្នកប្រាជ្ញ ១ ទៀតជាគំរប់ ៥ នឹងអាចារ្យទាំង ៤ គ្រានោះព្រះពោធិសត្វមកចាប់បដិសន្ធិ ក្នុងគភ៌នៃនាងសុមនាទេវី ជាអគ្គមហេសីនៃសិរិវឌ្ឍកសេដ្ឋី ក្នុងស្រុកបាចីនយវមជ្ឈកគ្រាម លុះដល់ខែ ១០ គ្រប់បរិបូណ៌ ក៏ប្រសូតចេញចាកអំពីឧទរ នៃមាតា លុះព្រះជន្មបាន ៧ វស្សា តារកមួយពាន់ជាបរិវារ ក៏សាងនូវសារណា ជីកនូវស្រះបោក្ខរណីជាទីល្បែង តែងលេងសព្វថ្ងៃ គ្រានោះមហាក្សត្រ ក៏នឹករលឹកដល់សុបិននិមិត្តថា នឹងបានអ្នកប្រាជ្ញមួយ ទៀត ម៉្លោះហើយមហាក្សត្រប្រើអមាត្យ ៤ នាក់ ចេញទៅដោយទ្វារទាំង ៤ អមដ្ឋា តំ ពិភ្ពា អាមាត្យទាំងឡាយឃើញនូវពោធិសត្វលេង មួយអន្ទើនឹង

ក្មេង ១ ពាន់ជាបរិវារ ក៏យកសេចក្តីក្រាបទូលដល់មហាក្សត្រ ទើបមហាក្សត្រប្រើអាមាត្យឲ្យទៅល្បង ពោធិសត្វ មានល្បងស្តេចជាដើម ពោធិសត្វក៏ដោះអស់ប្រស្នា មិនមានសេសសល់ រីឯព្រះបាទវិទេហរាស្ត្រ ស្តេចក៏មានព្រះរាជហឫទ័យត្រេកអរ សោមនស្ស នឹងពោធិសត្វដោយនូវការប្រស្នាក៏សូមពោធិសត្វ ជាបុត្រសេដ្ឋីថា ៖ សេដ្ឋី ហៃសេដ្ឋីអើយ ៖ ធាជិ អហំ ឥឡូវនេះ អញនឹងសូមចៅមហោសថជាបុត្តនៃអញ ទើបសេដ្ឋីផ្តាំបុត្រ ស្រេចកាលណា ក៏លើកបុត្រថ្វាយព្រះមហាក្សត្រ ស្តេចក៏មានសេចក្តីត្រេកអរ អនុញ្ញាតឲ្យសេដ្ឋីធ្វើជាក្រមក្រឹត្យជាស្តេច ចាប់ដើមតាំងអំពីថ្ងៃនោះមក សេដ្ឋីក៏លាវិលត្រឡប់ទៅកាន់គ្រឹហានៃអាត្មាវិញ បពិត្រអើយវីទឹងសរសេរតំណើរព្រះពោធិសត្វដោះនូវប្រស្នាទាំង ១៩ មានប្រស្នាស្តេចជាដើម មាន

ប្រស្នាកែវជាទីបំផុត ក៏សូរេចតែប៉ុណ្ណោះ ឯកាធិវសំ មានកាលសម័យថ្ងៃមួយព្រះបាទវិទេហរាស្ត្រ ក៏បានឃើញ បក្សីយទុំលើដង្គត់ឈើ បក្សីយឃើញមហាក្សត្រក៏មកលុតក្រាប ក្នុងទីចំពោះមុខ ទើបមហាក្សត្រដណ្តឹងទៅពោធិសត្វអំពីហេតុ ដែលបក្សីយក្រាបទូល ពោធិសត្វក៏ដោះស្រាយប្រស្នា អំពី បក្សីយ ថ្វាយព្រះមហាក្សត្រសព្វគ្រប់ប្រការ ព្រះមហាក្សត្រា ក៏មានសេចក្តីត្រេកអរនឹងពោធិសត្វនោះពេកក្រៃ តធាកា :ល ៗដ៏គ្រានោះមានបុរស ១ ឈ្មោះបិង្គុត្តរមាណព នៅ ក្នុងមិថិលានគរ ក៏ចេញទៅរៀនសិល្ប៍នឹងអាចារ្យទិសាបា-មោក្ខ ទើបអាចារ្យក៏ផ្សំបុត្រី ១ ដ៏មានសិរីសួស្តីប្រសើរ, ឯ មាណពនោះសោតក៏ជាមនុស្សកាឡកណ្ណី នៅរួបរួមនឹងស្រី នោះពុំបាន ក៏លាអាចារ្យមកជាមួយនឹងភរិយា ដល់ព្រៃកាល ណា ក៏បញ្ឆោតស្រីនោះឲ្យឡើងបេះផ្លែល្វា ហើយកាប់បន្លា ស្រាស់គល់ឈើនោះហើយដើរចោលទៅ ទើបស្តេចវិទេហ-

កស្ត្រទៅលេងព្រៃ ឃើញនាងនោះហើយសាកសួរដើមអស់សេចក្តី ក៏យកនាងមកអភិសេកធ្វើជាអគ្គមហេសី ហើយមហាក្សត្រក៏សន្មតឈ្មោះហៅនាងទុម្ពរ ។ មានកាលសម័យថ្ងៃមួយ នាងនឹងមហាក្សត្រក៏ជិះរាជរថចេញទៅប្រពាតព្រៃ នាងឃើញមាណពជាស្វាមីស្លៀកកំណាត់សំពត់ឈរទៀបក្លោងទ្វារហើយនាងញញឹមរកមហាក្សត្រ ។ ឃើញនាងញញឹមដូច្នោះកាលណា ក៏ក្រេវក្រោធកិរោធក្រៃ នាងក៏ទូលក្សត្រថ្វៃតាមតំណើរ ស្តេចពុំជឿទើបសួរអាចារ្យទាំង ៤ អាចារ្យទាំង ៤ ក៏ពុំជឿ ទើបសួរពោធិសត្វ ។ ក៏នាំមកនូវសេចក្តីប្រៀបធៀបថ្វាយមហាក្សត្រថា : ទេវ បពិត្រព្រះកូមិន្ទក្សត្រថ្លៃប្រសើរអើយ រីឯបុរសនោះជាប្តីនាងមែន ប៉ុន្តែឧបមាប្តីដូចជាត្រើយនាយសមុទ្រ នឹងត្រើយអាយសមុទ្រ យ៉ាងណា មនុស្សមានសិរីសួស្តី នឹងមនុស្សកាឡកណ្ណីជិតគ្នាមិន

បានក៏ដូច្នោះ, ទើបមហាក្សត្រក៏មានសេចក្ដីត្រេកអរនឹងពោធិ-សត្វ ទ្រង់ប្រទានមាសមួយសែនដំឡឹង នាងក៏សូមពោធិ-សត្វជាប្អូន ចាប់ដើមតាំងតែអំពីថ្ងៃនោះ, បពិត្រអើយ រីបញ្ញាពោធិសត្វរកបុគ្គលឯណា ១ នឹងប្រៀបពុំបាន ដោះអាថិប្រ-ស្នាឲ្យនាងបានរួចអំពីសេចក្ដីស្លាប់បាន ។ រីឯមានបុគ្គលមានសិរីនឹងកាឡកណ្ណីជាស្រេចតែប៉ុណ្ណេះ ។

អបរស្មឹ ទិវសេ កន្លងថ្ងៃទៃព្រះមហាក្សត្រទតទៅយល់ ពពែនឹងឆ្កែជាសំឡាញ់នឹងគ្នា ហើយស្ដេចក៏ពិ-ចារណាឃើញហេតុសត្វទាំងពីរ ក៏ចងជាប្រស្នាដណ្ដឹងអ្នកប្រាជ្ញទាំង ៤ រីឯអាចារ្យទាំង ៤ រកប្រស្នាឆ្កែនឹងពពែនោះពុំមានសេសសល់ឡើយ មហាក្សត្រក៏មានសេចក្ដីត្រេកអរនឹងពោធិសត្វ ក៏ទ្រង់ប្រទានទូរអាជានេយ្យនឹងរថ ។ រីឯអាចារ្យទាំង ៤ ទៅរៀនប្រស្នានឹងពោធិសត្វ ទើបមកឆ្លើយប្រស្នានឹងមហាក្សត្រ ស្ដេចទ្រង់ប្រទានអាជានេយ្យនឹងរថ

មួយម្នាក់ ៗ ម្ល៉ោះហើយនាងឧទុម្ពរ នាងគិតថា អ្នកទាំង ៤ ទៅរៀនដូច្នោះហើយ នាងលលាទៅកាន់សំណាក់មហាក្សត្រហើយទូលដណ្តឹងថា៖ ទេវ បពិត្រមហារាជអើយ ព្រះអង្គពុំគួរនឹងប្រទានព្រះរាជទ្រព្យដល់អាចារ្យទាំង ៤ ឲ្យស្មើនឹងចៅមហោសថឡើយ , ដ្បិតប្រស្នានេះគឺអាចារ្យទាំង ៤ រៀនអំពីមហោសថ ទើបមកដោះអាថ៌ប្រស្នាបាន រាជា តំ សុត្វា ព្រះរាជាបានស្តាប់ពាក្យនាងទូលដូច្នោះហើយក៏មានសេចក្តីត្រេកអរនឹងពោធិសត្វខ្លាំងក្រៃ ទើបព្រះចក្រី ដណ្តឹងនូវសិរីមេណ្ឌបញ្ហានឹងពោធិសត្វ សំដែងអំពីបុគ្គលពីរជំពូក ទើបពោធិសត្វក៏ដោះនូវសិរីមេណ្ឌបញ្ហា មួយអន្លើនឹងអាចារ្យទាំង ៤ ថ្វាយមហាក្សត្រសព្វគ្រប់ប្រការ មហាក្សត្រក៏មានសេចក្តីត្រេកអរក្រៃ គ្រានោះពោធិសត្វមានព្រះជន្មវស្សា ១៦ ឆ្នាំ នាងឧទុម្ពរក៏មកគិតរំពឹងពិចារណាថា៖ មហោសថប្អូនអញនេះមានព្រះជន្ម ១៦ ឆ្នាំហើយ គួរអញនឹងរក

កិរិយាឲ្យប្អូនអញ គិតដូច្នោះកាលណា ចូលទៅក្រាបទូលព្រះចក្រី ទើបព្រះចក្រីក៏អនុញ្ញាតឲ្យតាមចិត្តនាង ទើបទេ-វីនាងក៏ទៅកាន់សំណាក់នៃពោធិសត្វទូលសព្វគ្រប់ប្រការទើបពោធិសត្វបន្ទូលថា • ភទ្ទេ ម្នាលនាងដ៏ចំរើន ស្រីដែលមានទៅក្នុងនគរនេះក្រមមានលក្ខណា បើដូច្នោះគួរខ្ញុំនឹងលានាងចេញទៅស្វែងរកនគរក្រៅ ទូលតែម្ល៉ោះហើយពោធិសត្វក៏លានាងឧទុម្ពរចេញទៅស្វែងរកកិរិយា ៗ ត-ទា កាលេ ពួកគ្រានោះ ឯកោ សេដ្ឋី មានសេដ្ឋី-១ នៅស្រុកឧត្តរយាវមជ្ឈិមគ្រាម ក៏ថយទ្រព្យសម្បត្តិជាអ្នកកំសត់ទុគិត មានកូនក្រមុំ ១ ឈ្មោះនាងអមរា គ្រានោះនាងក៏យកនូវភោជនទៅជូនបិតានាងឯស្រែ ៗ ពោធិសត្តោ ពោធិសត្វ តំ ទិស្វា បានឃើញនាងអមរានោះកាលណា ក៏សាកសួរកិច្ចការជាអាថ៌ប្រស្នា នាងអមរាក៏ដោះ

ពុំមានសេស់សល់ ប្រាប់ដល់មាតាបិតាកាលណា គឺធ្វើនូវអាហារមង្គលឲ្យជាកិរិយានៃពោធិសត្វ លុះយូរបន្តិចទៅពោធិសត្វ ក៏ល្បងនានសត្វគ្រប់ប្រការ ហើយលាមាតាបិតាក្មេក ទៅកាន់សំណាក់នៃមហាក្សត្រ ទើបព្រះបក្រីទ្រង់ប្រទានមាស ១ ពាន់ដំឡឹង, រឺទឹងសរសើរដំណើរពោធិសត្វ បាននាងអំមកជាអគ្គមហេសីជាសូរេចតែប៉ុណ្ណោះ ។ ឯគ្រានិរសំ មានកាលសម័យថ្ងៃមួយ អាចារ្យទាំង ៤ ក៏ជំនុំគ្នាថា ឥឡូវនេះមហោសថបានអគ្គមហេសីជាស្រីមានប្រាជ្ញា បើដូច្នេះគួរយើងទំលាយមហោសថនេះពីមហាក្សត្រ, លុះគិតព្រមល្មមគ្នាធ្វើជាចោរ អាចារ្យសេនកលួចយកមាលាមណីរតន៍ អាចារ្យបុក្កុសលួចសុពណ៌មាលាមាស អាចារ្យទេវិន្ទលួចសុពណ៌បាទមាស យកទៅដាក់ក្នុងផ្ទះពោធិសត្វហើយញុះញង់មហាក្សត្រឲ្យស្តេចខ្ញាល់ ស្តេចក៏ពុំពិចារណាក៏ខ្ញាល់ទឹងពោធិសត្វ ម៉្លោះហើយពោធិសត្វក៏ឲ្យពតិមានទៅនាងអមរា

ហើយក៏ចេញចាកទៅនៅអាស្រ័យនឹងអ្នកស្រុកខ្ទាំង ,  គ្រានោះអស់មហាជនកើតកោឡាហល របស់គ្រប់គ្នាត្រិតពោធិសត្វចេញចាកអំពីគ្រឹហានៃអាត្មា  នាំអមកក៏ចាប់អាចារ្យទាំង ៤  ដោយនូវប្រាជ្ញានៃអាត្មាព្រោះហេតុចង់បាននាងជាភរិយា  នាំមកថ្វាយក្សត្រា  ក្សណៈនោះព្រះចក្រីក៏ពុំដឹងជាពោធិសត្វចេញទៅទីណា ៗ  ឥតជា  គ្រានោះទេវតារក្សាស្វេតច្ឆត្រនៃមហាក្សត្រ  ចោទនូវប្រស្នា ៤ បទ  នឹងស្ដេច  ទើបព្រះចក្រីឲ្យហៅអាចារ្យទាំង ៤  មកដោះក៏ពុំរួចឡើយ  ស្ដេចក៏ប្រើអមាត្យទាំង ៤  ឲ្យទៅស្វែងរកពោធិសត្វ  លុះបានឃើញពោធិសត្វនៅនឹងនាយស្រុកខ្ទាំង  ក៏អញ្ជើញតាមព្រះបន្ទូលនៃមហាក្សត្រ  ទើបពោធិសត្វមកដល់កាលណា  ក៏ដោះនូវប្រស្នាដែលមហាក្សត្រដណ្ដឹងចប់ស្រេច  ក៏ដោះប្រស្នាដែលទេវតាដណ្ដឹងមហាក្សត្រ

ពុំមានសេសសល់ ទើបទេវតាបូជានូវប្រអប់មាស ព្រះចក្រីក៏លើកពោធិសត្វ តំកល់ឲ្យជាទីសេនាបតី ចាប់ដើមអំពីថ្ងៃនោះពោធិសត្វ ក៏ទឹងមានសម្បត្តិច្រើន ៗ ឯកានិវសំ មានកាលសម័យថ្ងៃមួយ អាចារ្យទាំង ៤ ក៏ជំនុំគ្នារកឧបាយកលនឹងសម្លាប់ពោធិសត្វ ក៏នាំគ្នាចូលទៅកាន់សំណាក់នៃពោធិសត្វ ហើយដណ្តឹងនូវប្រស្នា , ពោធិសត្វក៏ដោះដោយប្រាជ្ញាចិត្តថ្លៃវិសេស ទើបអាចារ្យទាំង ៤ នាំយកសេចក្តីក្រាបទូលដល់ព្រះចក្រី ៗ ហេតុតែពុំបានពិចារណា ក៏ក្រេវក្រោធកិភេធក្រៃ ក៏ទ្រង់ប្រទាននូវព្រះខ័នទៅក្នុងដៃ នៃអាចារ្យសេនក មួយអន្លើនឹងអាចារ្យទាំង ៣ ឲ្យសម្លាប់ពោធិសត្វ លុះដល់មជ្ឈិមយាម ព្រះចក្រីភ្ញាក់នឹករលឹកដល់ពោធិសត្វ ក៏ខ្សឹកខ្សួលរំជួលក្នុងព្រះទក នាងបទុមា នាងជ្រាបថាមហាក្សត្រខ្សឹកខ្សួល ព្រោះស្តេចឲ្យអាចារ្យទាំង ៤ សម្លាប់មហោសថដូច្នោះគាលណា នាង

ក៏ញុំាងក្សត្រាឲ្យស្រាកស្រួល ហើយផ្ដុំលើគ្រែក្រឡាបន្ទំ ក៏លក់ពុំដឹងស្មារតី ហើយស្រីថ្លៃ នាងក៏សរសេរសំបុត្រជាពត៌មាន ថ្វាយពោធិសត្វឲ្យជ្រាបខ្លូវសេចក្ដីនោះ លុះពោធិសត្វជ្រាបសព្វគ្រប់តាមសេចក្ដីសំបុត្រកាលណា ហេតុតែបញ្ញាបារមីថ្លៃ ក៏ដោះរួចខ្លួនអំពីក្សេណក្ស័យ លុះព្រះចក្រីជ្រាបសព្វគ្រប់ថាអាចារ្យទាំង ៤ នោះ ជាអ្នកញុះញង់ឲ្យសម្លាប់ពោធិសត្វដូច្នោះ ក្សត្រាក៏ក្រេវក្រោធគីពេធក្រៃ ញុំាងពេជ្ឈឃាតឲ្យនាំអាចារ្យទាំង ៤ ទៅសម្លាប់ ហើយពោធិសត្វក៏សូមទោសនឹង ព្រះរាជា ព្រះរាជាក៏អត់ទោសពុំបានសម្លាប់ ហេតុតែបុណ្យបារមីវិសេសថ្លៃ នឹងរកបុគ្គលឯណា ១ មកប្រៀបនឹងប្រាជ្ញានៃពោធិសត្វពុំបាន បពិត្រអើយ រ-ប្រាជ្ញាបុណ្យបារមីនៃព្រះមហោសថ នឹងសេកសោមបណ្ឌិតក៏រក្សាអស់ប្រជាជន មានមហាក្សត្រាធិរាជជាដើម ឲ្យបាន

នូវសេចក្ដីសុខ គ្រប់គ្នាទីទៃ ៗ គ្រានោះមានស្ដេចមួយ ឈ្មោះសន្ធលរាជ សោយរាជ្យនៅក្រុងសន្ធលរដ្ឋ នឹងស្ដេចចុល្លណី មានអាចារ្យកេវដ្តព្រាហ្មណ៍ ជាអ្នកប្រៀនប្រដៅ សោយរាជសម្បត្តិក្នុងនគរឧត្តរបញ្ចាល អគ្គមហេសីឈ្មោះ នាងនន្ទាទេវី មានបុត្រី ១ ឈ្មោះនាងបញ្ចាលចន្ទី មានរាជបុត្រា ១ ឈ្មោះចៅបញ្ចាលកុមារ ស្ដេចចុល្លណីមា ឫទ្ធីបារមីខ្លាំង ច្បាំងឈ្នះអស់ស្ដេចទាំងពួង ក៏លើកពល ១៨ អក្ខោភិនីមកពោមនគរមិថិលា ដើម្បីនឹងកាត់យក នៃសេនាស្ដេចវិទេហរាជ ព្រះពោធិសត្វក៏ផ្ចាញ់ដោយប្រាជ្ញាបារមី ឲ្យរួចអំពីភ័យ គឺសេចក្ដីអន្តរាយខ្ចាត់ខ្ចាយដោយព្រះប្រាជ្ញាទិព្វថ្លៃនៃពោធិសត្វ មិនតែប៉ុណ្ណោះសោត ពោធិសត្វមានឫទ្ធីបារមីខ្លាំង ញុំាំងជនឲ្យជីកនូវឧមង្គ ចាប់យកទាំងបុត្រីបុត្រា ភរិយា មកថ្វាយព្រះបាទវិទេហរាជ នាងបញ្ចាលចន្ទី ក៏បានជាអគ្គមហេសីនៃស្ដេចវិទេហរាជ ហេតុតែ

ព្រោះជាបុណ្យបារមី ស្តេចចុល្លណី និងព្រះបាទវិទេហរាជ មិញ ក៏មានហឫទ័យស្មោះសរ និងគ្នាទៅវិញទៅមក ពុំដែលដាច់ឡើយ ព្រះបាទចុល្លណីក៏ចាប់គ្នាជាបុត្រ ចាប់ដើមតាំងតែអំពីថ្ងៃនោះ លុះនាងបញ្ចាលចន្ទី នៅរួបរួមនឹងព្រះបាទវិទេហរាជបាន ៣ ឆ្នាំ នាងក៏ទ្រង់គភ៌គ្រប់ខែ ១០ បរិបូណ៌នាងក៏ប្រសូតរាជបុត្រ ១ នាងក៏សន្មតឈ្មោះហៅយាវុត្តកុមារ លុះចំរើនធំឡើង ព្រះវរាជបិតាក៏សោយទិវង្គតលែងខន្ធទៅ ព្រះមហោសថក៏លើករាជ-បុត្រឲ្យសោយរាជសម្បត្តិក្នុងនគរមិថិលា ទើបពោធិសត្វ ក៏នឹករលឹកដល់ពាក្យប្តេជ្ញា នឹងស្តេចចុល្លណីថាទៅកាន់នគរឧត្តរបញ្ចាល ហើយលារាជកុមារទៅកាន់នគរឧត្តរបញ្ចាល ស្តេចចុល្លណីក៏មានសេចក្តីត្រេកអរនឹងពោធិសត្វ ទ្រង់ប្រទានស្រុកប៉ែតសិប រកក្នុងនគរឧត្តរបញ្ចាលនោះ មាននាងបរិព្វា-ជី ១ ឈ្មោះភេរីបរិព្វាជីកាលហើយពោធិសត្វ ក៏ដោះនូវ

LIBRARY

ប្រស្នា នឹងនាងបរិព្វាជីនោះ ឥតមានទើសទាល់សល់ចំ-
ពាក់ឡើយ ; ព្រះបាទចុល្លណីលើក ព្រះពោធិសត្វជា
សេនាធំ ពោធិសត្វមានសេចក្តីសង្ស័យឲ្យនាងបរិព្វាជី ទៅ
សួរអស់ប្រស្នាទាំង ៦ គឺនាងធាត្វាកទេវី ជាព្រះកន្លោង
១ នាងនន្ទាជាទេវី ១ ពៅតិក្ខនមន្ត្រីជាសម្តេចអនុជ ១
ធនុសេកកុមារ ១ អាចារ្យកេវត្តព្រាហ្មណ៍ ១ ពោធិសត្វ ១
ព្រះបាទចុល្លណី ក៏ដោះអាថ៌ប្រស្នាជាស្ងួរទេ នាងបរិព្វាជី
ក៏ប្រាប់ដល់ពោធិសត្វឥតមានសន្ទិះឡើយ ។ ក្រោ សា-
ធរៅ បពិត្រសព្វស្រេចផងទាំងឡាយអើយ សម្តេចព្រះពុទ្ធ-
អង្គនាំមកនូវព្រះធម៌វិសេសទេសនា ជាសណ្តាប់នៃពុទ្ធបរិស័ទ
ទាំងពួងស្រេច ទើបសម្តេចព្រះសាស្តាចារ្យ ទ្រង់រួមនូវ
កំណើតជួប្នះ អាចារ្យសេនក បេរិលវិញមកជាព្រះ
កស្សប អាចារ្យបុក្កុសបានមកជាព្រះសោតិកកិត្តិ អាចារ្យ
កាមិនបានមកជាព្រះកទនត្ថេរ អាចារ្យទេវិន្ទ បានមកជាព្រះ

ពានត្ថេរ , អាចារ្យកេវដ្តព្រាហ្មណ៍ បានមកជាទេវទត្តត្ថេរ នាងឆឡាក់ទេវីបានជានាងជុនលនន្ទត្ថេរី នាងបញ្ចាលចន្ទី បានជានាងសុន្ទរីភិក្ខុណី សារិកាបានជានាងអង្គលិកាភិក្ខុណី ព្រះបាទវិទេហរាជ បានជាកាឡុទាយិត្ថេរ នាងឧទុម្ពរ បានជានាងទិដ្ឋមង្គលិកាភិក្ខុណី នាងភេរីបរិព្វាជី បានជានាងឧប្បលវណ្ណាថេរី មាតាបិតា បានមកជាពុទ្ធមាតាបិតា នាងអមរា បានមកជានាងពិម្ពា ពៅតិក្ខមន្ត្រីបានជាឆន្នត្ថេរ ឆ្ប សេកកុមារ បានជាពហុលត្ថេរ សេកសោមបណ្ឌិត បានជាអនន្ទត្ថេរ ព្រះមហោសថ គឺសម្តេចព្រះពុទ្ធអង្គ ។ មហោសថជាតកាំ បញ្ចមំ និដ្ឋិតំ ។ មហោសថ-ជាតក ជាតំរប់ ៥ ចប់ស្រេចតែប៉ុណ្ណោះ ។

# ៣ _ ភូរិទត្ត ជាតក

គ្រានេះនឹងសំដែងជាតកជាគំរប់ ៦ តទៅទៀត, គ្រានោះអស់ពពួកភិក្ខុផងទាំងឡាយ សរសើរតំណើរអំពីការអស្ចារ្យរបស់ព្រះអង្គ ។ បានជ្រាបកាលណា ក៏នាំនូវអតីតនិទាន មានពាក្យព្រះបាលីថា : អតីតេ ភិក្ខវេ ពារាណសិយំ ព្រហ្មទត្តោ រាជា នាម រជ្ជំ ការេសិ ។ អតីតេ ក្នុងកាលអតីតកន្លងទៅហើយ ភិក្ខវេ ម្នាលភិក្ខុផងទាំងឡាយអើយ គ្រានោះមានមហាក្សត្រាធិរាជ មួយព្រះអង្គ ទ្រង់ព្រះនាម ព្រះបាទព្រហ្មទត្ត សោយរាជ្យសម្បត្តិក្នុងនគរពារាណសី មានរាជបុត្រប្រុស ១ ឈ្មោះទៅព្រហ្មទត្តកុមារ លុះព្រះរាជបុត្រនោះ ចំរើនធំឡើងក៏បានជា មហាឧបរាជ ព្រះវររាជបិតាក៏មានសេចក្ដីរង្កៀសនឹងបុត្រនោះ ព្រោះហេតុតែរាជសម្បត្តិ បុត្រ

នោះក៏ចេញទៅទៀបឆ្នេរសមុទ្រ ក៏បានរួបរួមនឹងនាងនាគ មានព្រះរាជបុត្រពីរ ឈ្មោះចៅសាគរ ១ នាងសមុទ្ទជាតិ ១ មិត្តអច្ចយេន លុះឥតអំពីបិតាទៅកាលណា ក៏បានមកសោយរាជ្យក្នុងនគរបិតាវិញ , រីឯនាងនាគត្រឡប់វិលទៅកាន់ពិភពនៃនាគវិញ , ចៅសាគរនឹងនាងសមុទ្ទជាតិមកមួយអន្លើនឹងបិតា ហើយបិតាក៏ញ៉ាំងជនឲ្យជីកស្រះឲ្យជាទីល្បែងនៃកូនទាំងពីរតាមសណ្តាប់នៃមាតា ឃរេកោ កា ជួរចោ គ្រានោះមានអណ្តើកមួយ ក៏ករទៅក្នុងស្រះនោះ តំ ទិស្វា កូនទាំងពីរឃើញអណ្តើកនោះកាលណា ក៏ស្រែកយំខ្លាំងក្រៃ លុះជ្រាបដល់បិតាកាលណា ក៏ឲ្យមហាជនចាប់ទាញនូវអណ្តើកនោះមកនឹងសម្លាប់ រីឯអណ្តើកនោះក៏បញ្ឆោតមហាជនឲ្យយកទៅបង្ហែលក្នុងស្ទឹងយមុនា គ្រានោះមាននាគកម្មោះ៤នាក់កំពុងលេងនៅទីនោះក៏ចាប់យកអណ្តើកនោះទៅ រីឯអណ្តើកនោះក៏ដោះស្រាយថាអាត្មាឯងនេះជា

រាជទូត , ព្រះបាទធតរដ្ឋនាគរាជស្តាប់អស់សេចក្តីថាអណ្តើក ជារាជទូតនៃស្តេចព្រហ្មទត្តមែន ហើយប្រើនាគកម្លោះឲ្យជូនអណ្តើកនោះឡើងមកដើម្បីនឹងដណ្តឹងនូវពត៌មាន ហើយអណ្តើកក៏បញ្ឆោតនាគកម្លោះទាំង ៤ នោះ ហើយវារចុះទៅក្នុងស្រះយមុនា នាគទាំង ៤ ក៏ទៅកាន់សំណាក់នៃស្តេចព្រហ្មទត្ត ក៏ទូលតាមសេចក្តី ដែលអណ្តើកទូលថា ស្តេចព្រហ្មទត្តនឹងថ្វាយរាជបុត្រីទៅព្រះបាទធតរដ្ឋនាគរាជ , ព្រះបាទព្រហ្មទត្តក៏ត្មះតិះដៀលទៅពូជអំបូរនៃព្រះបាទធតរដ្ឋនាគ-រាជ , នាគទាំង ៤ បានស្តាប់ព្រះបន្ទូលព្រះបាទព្រហ្មទត្តត្មះតិះដៀលដូច្នោះហើយក៏ក្រេវក្រោធពិរោធក្រៃ នាំយកសេច-ក្តីចូលទៅក្រាបទូលព្រះបាទធតរដ្ឋនាគរាជ តំ សុត្វា បពិត្រអើយ កាលណាបើព្រះបាទធតរដ្ឋនាគរាជបានស្តាប់ពាក្យនាគទាំង ៤ នោះក្រាបទូលដូច្នោះហើយ ក្បត្រាក៏ឲ្យ

នាគទាំងឡាយមកសំដែងឫទ្ធិនៃអាត្មាទីទៃ ៗ ញុំាងស្តេច
ព្រហ្មទត្តឲ្យភិតភ័យ ព្រះបាទព្រហ្មទត្តរាជឃើញនូវឥទ្ធិឫទ្ធិ
នៃនាគដូច្នោះកាលណាក្សត្រាក៏ភិតភ័យ ញាប់ញ័រ រន្ធត់ក្នុង
កាយា ក្សត្រាក៏លើករាជបុត្រីថ្វាយទៅព្រះបាទទត្តរថនាគ-
រាជ លុះនាងសមុទ្ទជាតិនៅរួបរួមមួយអន្លើនឹងព្រះបាទទត្ត
រថនាគរាជ គ្រានោះព្រះបាទទត្តរថនាគរាជក៏ហាមប្រាមអស់
ពពួកនាគផងទាំងឡាយថា បើនាគឯណាកាឡាខ្លួនជាពស់
ឲ្យនាងសមុទ្ទជាតិនោះឃើញហើយ ស្តេចយកទោសអ្នកនោះ
ឯងដល់ជីវិត លុះយូរបន្តិចទៅនាងក៏មានរាជបុត្រនោះ ៤
នាក់ ឈ្មោះចៅសុទស្សកុមារ ១, ចៅភូរិទត្តកុមារ ១, ចៅសុ-
ភោគកុមារ ១ , ចៅអរិដ្ឋកុមារ, ១ ៗ រីឯចៅភូរិទត្តកុមារនោះ
គឺព្រះពោធិសត្វ មានប្រាជ្ញាអាចកាត់នូវប្រស្នានឹងសម្តេចឥន្ទ្រ
ធិរាជ, ចៅអរិដ្ឋកុមារលុះឮថាម្តាយនៃខ្លួនជាមនុស្សវិស័យ មាន
កាលមួយថ្ងៃក៏និម្មិតនៃអាត្មាជាពស់ មាតាលុះឃើញចៅអ-

រិដ្ឋដូច្នោះក៏ស្រែកសម្រែក នាះខ្លាំងក្រៃ ប្រាប់ដល់បិតាក៏ក្រេវក្រោធពេកក្រៃ ត្បិតទៅអរិដ្ឋទទឹងអាជ្ញានិងព្រះចក្រី ទើបក្សត្រីនាងទូលតាមសេចក្តី ត្បិតទៅអរិដ្ឋនោះនិម្មិតអាត្មាជាពស់ ក៏នាងក្រទៅត្រូវក្អក ហើយប្រានទម្លាក់ទៅ ព្រះបិតាក៏ពុំយកទោសឡើយ ព្រះបាទទត្តរថនាគពជបែងចែកសម្បត្តិឲ្យកូនទាំង ៤ នាក់ស្មើគ្នា គ្រានោះពោធិសត្វមានហឫទ័យក្នុងទឹកទឹងចង់ចាំសីលចំរើនមេត្តាភាវនា ក៏លាមាតាបិតាបុត្រភរិយា ចេញទៅចាំសីលឧបោសថក្នុងពិភពនៃនាគនោះ អស់ពពួកនាងនាគទាំងឡាយក៏យកនូវតូរ្យតន្ត្រីទៅលេងថ្វាយព្រះពោធិសត្វ ក៏ព្រះអង្គមិនធ្មន់នឹងតូរ្យតន្ត្រីនោះក៏ចេញមកកាន់ឋានមនុស្សលោក ហើយនិម្មិតនៃអាត្មាប៉ុនក្បាលនង្គ័លដេកផ្ទាល់លើក្បាលដំបូក ចាំសីលជាអម្ពុងយប់ថ្ងៃ យូរក្រៃពេក ; គ្រានោះមានព្រាហ្មណ៍នេសាទ ១ មាន

កូន ១ ឈ្មោះសោមទត្ត ចូលទៅក្នុងព្រៃនោះឃើញពោធិ-សត្វចាំសីលនៅទីនោះ អស់នាងនាគទាំងឡាយដែលនាំកម្រងផ្កាមកថ្វាយពោធិសត្វវិញ ក៏មុជជ្រែកទៅកាន់ពិភពនាគវិញ, រីឯយនេសាទក៏ដណ្ដឹងពោធិសត្វសព្វគ្រប់ប្រការ ពោធិសត្វក៏ពឹងគិតពិចារណាថា ព្រាហ្មណ៍នេះ បើអញពុំឲ្យសេពសោយសម្បត្តិក្នុងពិភពនៃអញនោះ ព្រាហ្មណ៍នេះសំមក់នឹងឲ្យអន្តរាយនៃសីលអញ. ពោធិសត្វគិតដូច្នោះកាលណា ក៏នាំព្រាហ្មណ៍មួយអន្លើនឹងកូនឲ្យទៅសោយសម្បត្តិក្នុងពិភពនៃនាគនោះ ឯព្រាហ្មណ៍ជាបិតានឹងសោយសម្បត្តិនោះក៏ពុំបាន ក៏នាំកូនឡើងមកកាន់ឋានមនុស្សលោកវិញ ព្រាហ្មណ៍នោះក៏នាំបុត្រដើរទៅកាន់ផ្ទះវិញ លុះភរិយានោះឃើញបុត្រនឹងបិតាកាលណា ក៏សាកសួរដឹងអស់កិច្ចការថានឹងចង់បួសហើយក៏ខឹងក្រទីក្រទា ប្រវាចបាននូវវែកក៏វាយនូវខ្នងនៃបិតាព្រួសស្រូវផាំង ១ តគោ បង្កាយ ចាប់ដើម

អំពីថ្ងៃនោះ បិតានឹងបុត្រក៏រកបរបាញ់ដូចកាលសព្វដងរៀង
មក ។ គាថា ទក្ខិណាមហាសមុទ្ទេ និសា
សិម្ពលី វសិ គ្រានោះមានគ្រុឌពជស្ថិតនៅលើចុងរកា
ឯត្បូងមហាសមុទ្រ ក៏ឆក់ពាំយូរក្បាលនាគពជឡើងទៅ រីឯ
នាគក៏មានសេចក្តីភិតភ័យ យកកន្ទុយពាក់ព័ន្ធវ័ណ្ណាដើមរកា
រីឯដើមរកានោះ ក៏រេគរលើងទៅដោយកម្លាំងនាគនឹងគ្រុឌ
ដើមរកានោះជាអាស្រមបថនៃមហាឥសី ហើយគ្រុឌក៏មក
ដណ្តឹងនូវផលបាបនឹងផលបុណ្យនឹងតាបស ទើបតាបសក៏
ប្រាប់សព្វគ្រប់ប្រការ គ្រុឌក៏មានសេចក្តីត្រេកអរ ហើយ
ឲ្យមន្តអាលម្ពាយទៅតាបសនោះ តាបសក៏រៀនយកនូវ
មន្តនោះ គាថា ឃរុំ សោ គ្រានោះមានបុរសម្នាក់ជា
ព្រាហ្មណ៍កំសត់នៅក្នុងនគរពារាណសី ជាអ្នកជំពាក់បំណុល
នៃព្រាហ្មណ៍ដទៃ ហើយក៏ដើរចូលទៅក្នុងព្រៃដើម្បីនឹងឲ្យ
ស្លាប់ គំ ធិ ស្វា ហើយឃើញនូវតាបសមហាឥសីនោះក៏ចូល

ទៅបំរើនៃមហាឥសីនោះ មហាឥសីក៏ឲ្យបុរសរៀនយកនូវ
មន្តនោះ រីឯបុរសនោះរៀនមន្តបានស្រេចកាលណា ក៏ក្រាប
បង្គំលាត្រឡប់វិលមកវិញ គ្រានោះអស់ពួកនៃនាងនាគទាំង
ឡាយក៏យកកែវទៅថ្កល់លើត្បូងខ្ជាប់ លុះឮបុរសស្វាធ្យាយ
មន្តនោះ ក៏ស្មានថាសុបណ្ណគ្រុឌ មានសេចក្តីភិតភ័យ ញ័រ
រន្ធត់ក៏ជ្រែកប្រថពីចោលកែវនៅក្នុងទីនោះ បុរសក៏រើសយក
កែវនោះ ; គ្រានោះព្រាហ្មណ៍នេសាទនឹងសោមទត្តជាកូនក៏
ដើរចូលទៅក្នុងព្រៃ ដើម្បីនឹងសម្លាប់នូវសត្វអម្រឹគបានឃើញ
បុរសឈ្មោះអាលម្ពាយ កាន់យកនូវកែវនោះក៏មានសេចក្តី
ប្រាថ្នាចង់បានហើយក៏សូមទិញនូវកែវនោះ នឹងឲ្យនូវវត្ថុមាន
មាសជាដើម អាលម្ពាយនោះក៏ពុំឲ្យឡើយ ព្រោះហេតុ
អាលម្ពាយចង់បានពស់នាគរាជ ទើបនេសាទព្រាហ្មណ៍
ក៏នាំអាលម្ពាយទៅកាន់ទីដំបូក ដែលពោធិសត្វចាំសីលទៅ

ពីនោះ រីឯសោមទត្តជាកូននោះក៏ប្រាសចោលបិតា ប្រកាស
អស់ទេព្តាស្រេចកាលណា ក៏ចូលទៅក្នុងព្រៃបួសជាមហាឥសី
ក៏ចំរើនឈានទាំងអភិញ្ញា លុះស្លាប់ទៅក៏បានទៅកើតក្នុងព្រហ្ម-
លោក រីឯអាលម្ពាយក៏ឲ្យកែវទៅនឹងសាទព្រាហ្មណ៍នោះ
រីឯកែវនោះក៏ធ្លាក់ចុះទៅក្នុងធរណី ទៅកាន់ពិភពនៃនាគវិញ
អាលម្ពាយក៏ចាប់ពោធិសត្វដាក់ក្នុងកំប្រោង ហើយនាំទៅ
កាន់ស្រុកទាំងនគរតាមតែអាលម្ពាយប្រើ ធ្វើដូចម្តេច ក៏ធ្វើ
បានឲ្យមហាជនមើល បានមាសប្រាក់ច្រើន លុះថ្ងៃពេញ
បូណ៌មីក៏នាំទៅកាន់សំណាក់ព្រះមហាក្សត្រាធិរាជ ក្នុងនគរ
ពារាណសី គ្រានោះមាតាពោធិសត្វនាងក៏ផ្ទុំលក់ យល់
និមិត្តហាក់ដូចជាស្លាប់ខ្លួននាង ឬ ស្លាប់កូននាង ម្ល៉ោះ
ហើយនាង ក៏សោយសោកទាំងពោធិសត្វ ដ្បិតខ្ជាត់
អំពីនាង ទៅនៅចាំសីល នៅឋានមនុស្សលោក
គ្រានោះកូនទាំង ៤ គឺចៅសុទស្ស ១ ចៅសុភោគ ១

ចៅអរិដ្ឋ ១ នាងអច្ចុមុខី ១ ដឹងសព្វគ្រប់អស់សេចក្ដីហើយ ក៏នាំគ្នាឡើងមកកាន់ឋានមនុស្សលោក , រីចៅអរិដ្ឋឲ្យគេនៅឋានទេវតា , ចៅសុភោគទៅកេនៅព្រៃហិមពាន ចៅសុខស្សភៀសខ្លួនជាមហាឥសី នាងអច្ចុមុខីភៀស ជាកញ្ញាញ់ចេកស ដើរទៅកាន់ទីដែលអាលម្ពាយ ដំកល់ទុកនូវពោធិសត្វ , បពិត្រអើយកាលណាបើពោធិសត្វបានឃើញព្រះរៀមទឹងនាងអច្ចុមុខី ជាប្អូនស្រីក៏ចេញអំពីកំប្រោងលូនចូលមកក្រាបលើព្រះបាទ ទឹកនេត្រាហូរស្រក់សស្រាក់ ក៏ត្រឡប់វិលចូលទៅក្នុងកំប្រោងវិញ គ្រានោះ អាលម្ពាយបានឃើញនូវហេតុនោះ ក៏ដណ្ដឹងទៅតាបស ក្រែងពោធិ-សត្វទាំ រីឯតាបសសោត ក៏អួតនូវមន្តនៃអាគ្នាក្ងៀវក្លាក្រៃអ្នកទាំងពីរកើតបដិប័ក្ខទាស់ទែងគ្នា ទើបតាបសហៅនាងអច្ចុ-មុខីឲ្យខ្ជាក់ពិសបីដុំ មកដាក់លើបាតដៃ ស្រែកប្រកាសថា

អន្តរាយហើយ ៗ ពាក្យនោះក៏ជ្រាបដល់មហាក្សត្រ ទើប
មហាក្សត្រមកដណ្តឹងនូវហេតុនោះនឹងតាបស ទើបតាបស
ក៏ក្រាបទូលស្តេច ឲ្យបញ្ឈាដ៏ករណ្តៅនោះបី រូបហើយ
តាបស ក៏ចាប់យកពស់ពិសនោះ បោះទៅក្នុងរណ្តៅ
នោះ ក៏ឆេះហុយឡើងជាផ្សែង ទៅលើអាលម្ពាយឈរ
ទៀបនៅទីនោះ ក៏បង្កើតទៅជាឃ្មង់រលៅ ឯព្រាហ្មណ៍
នេសាទលុះឮថាអាលម្ពាយកើតឃ្មង់ដូច្នោះ ក៏ចុះទៅដួតទឹក
ស្ទឹងលាងបាប គ្រានោះហៅសុខស្សក៏ថ្លែងប្រាប់មហាក្សត្រ
សព្វគ្រប់ប្រការ ក៏នាំពោធិសត្វទៅកាន់ពិភព នៃនាគវិញ
ក៏ព្រះអង្គផ្ទុំលើក្រឡាបន្ទំ គ្រានោះហៅសុភោគក៏រួបនូវដើង
នៃនាយនេសាទនោះ ទៅកាន់ពិភពនៃនាគ ទើបហៅអជ្ជ
ពោលនូវពាក្យសរសើរ នូវបុគ្គលជាអ្នកគបជា ព្រះពោធិ-
សត្វក៏ត្នះតិះដៀលនៃហៅអជ្ជ ទើបសំដែងព្រះធម៌វិសេស
ទេសនា ឲ្យជាសណ្តាប់ប្រាប់អស់បរិស័ទនៃនាគទាំងឡាយ

បពិត្រអើយ ព្រះពោធិសត្វសោត ព្រះអង្គរក្សាសីលឧ-បោសថ លុះសោយវិលាល័យក្ស័យព្រះជន្មទៅ បានទៅកើតក្នុងសួគ៌ទេវលោក មួយអន្លើនឹងបរិស័ទទាំងឡាយ ។ ជាតកំ សមោធានេត្វា ទើបព្រះអង្គប្រជុំមកនូវជាតក , រីឯនេសាទព្រាហ្មណ៍ បានមកជាទេវទត្ត រីឯសោមទត្ត បានជាអស្សត្ថេរ , រីឯនាងសមុទ្ទជាតិ បានជានាងមហាមាយា រីព្រះបាទធតរដ្ឋនាគរាជ បានជាព្រះបាទស្រីសុទ្ធោទនមហារាជ , រីឯនាងអច្ចិមុខី បានជានាងឧប្បល-វណ្ណា រីឯចៅសុទស្ស បានជាព្រះសារីបុត្តត្ថេរ រីចៅសុភោគ បានជាមហាមោគ្គល្លានត្ថេរ, រីចៅអរិដ្ឋ បានជាលក្ខណត្ថេរ, រីភូរិទត្ត គឺអង្គព្រះសម្មាសម្ពុទ្ធ ។ ភូរិទត្តជាតកំ ឆដ្ឋមំ និដ្ឋិតំ បពិត្រអើយ រីយើងនឹងសរសើរតំណើរកាលព្រះអង្គយោនយកកំណើតកើតជាភូរិទត្តមិញ តំរប់ ៦ ជាតិ ដ៏ជាសួរបទនូវប្រការអម្បាលនេះហោង ។

# ៣- បន្ធកុមារជាតក

គ្រានោះ នឹងសំដែងក្នុងជាតកជាគំរប់ ៧ ជាតិទៀត
វិញទៀត ។ ករជាសិ លុទ្ធកមោសីតិ ឥទំ
សត្ថា គិជ្ឈកូដបព្វតេ វិហរន្តោ ទេវទត្តំ
អារព្ភ កថេសិ ។ សត្ថា ព្រះសាស្តា វិហរន្តោ
កាលគង់នៅ គិជ្ឈកូដបព្វតេ លើកំពូលនៃភ្នំឈ្មោះ
គិជ្ឈកូដ អារព្ភ ចំពោះហើយ ទេវទត្តំ នូវទេវ-
ទត្ត កថេសិ សំដែងហើយ ឥមំ ធម្មទេសនំ
នូវព្រះធម៌ទេសនា ឥតិអាទិកាថាបទេន ដោយបទ
គាថាមានដូច្នេះជាដើម ករជាសិ លុទ្ធកមោសិ ឥ-
តិ ថាដូច្នេះ, តទា កាលេ ក្នុងគ្រានោះ ភិក្ខុស-
ង្ឃោ អស់ភិក្ខុសង្ឃផងទាំងឡាយ សរសើរបុណ្យបារមី
នៃសម្តេចព្រះដ៏ជាគ្រូ បង្កើតជាអស្ចារ្យ ទើបព្រះអង្គនាំអតីត

និទាន កាលដែលព្រះអង្គទៅកើតជានាយឈ្មួញក្នុងនគរសាវត្ថី ទេវទត្តក៏ទៅកើតជាប្អូន ប៉ុន្តែម្តាយទីទៃ កើតបដិប័ក្សនឹងពោធិសត្វអំពីដូនតាស់ ក៏បែកទ្រូងស្លាប់ទៅ លុះដល់ព្រះអង្គបានត្រាស់ ក៏បានមកជាទេវទត្តក៏ញុំាងព្រះបាទអជាតសត្រូវឲ្យសម្លាប់នូវបិតា ក៏សូមយកនូវខ្មាន់ធ្នូអំពីព្រះបាទអជាតសត្រូវមកសម្លាប់ព្រះអង្គ ទើបព្រះអង្គទូន្មាននូវខ្មាន់ធ្នូនោះ ឲ្យបានលុះដល់មគ្គផល ទើបខ្មាន់ធ្នូក៏សូមផ្នួសបួសក្នុងព្រះសាសនា ទើបទេវទត្តក៏ឡើងលើកំពូលភ្នំគិជ្ឈកូដបព៌តប្រមៀលថ្មដើម្បីនឹងសម្លាប់ព្រះអង្គ ក៏ព្រះធរណីស្រូបទេវទត្តទៅក្នុងអវចីនរកក្នុងគ្រាកាលនោះ ទើបព្រះអង្គនាំអតីតនិទានមកសំដែងថា ភិក្ខវេ ម្នាលភិក្ខុទាំងឡាយអើយ អតីតេ កាលេ ក្នុងកាលកន្លងទៅហើយ ឯកោ រាជា គ្រានោះមានមហាក្សត្រាធិរាជ ១ អង្គ ទ្រង់ព្រះនាមព្រះបាទវេស្សវត្តីរាជ មានព្រះរាជបុត្រ ១ ឈ្មោះព្រះ

បាទឯកករាជ សោយរាជសម្បត្តិក្នុងនគរឈ្មោះបុប្ផវតី ក្នុង
ស្រុកពារាណសីនគរនោះ រីឯព្រះបាទឯកករាជមានព្រះរាជ
បុត្រ ១ ឈ្មោះព្រះចន្ទកុមារ ទើបព្រះបាទឯកករាជដំកល់តំ-
កើងឲ្យព្រះ ចន្ទកុមារ ឡើងជាមហាឧបរាជ មានអាចារ្យ
កណ្ឌហាលព្រាហ្មណ៍ ១ មហាក្សត្រឲ្យជាសុភាបង្គាប់ក្តីអ្នក
ផងទាំងឡាយ រីឯព្រាហ្មណ៍នោះក៏កាត់ក្តីពុំត្រឹមត្រូវដោយនូវ
គន្លងធម៌ ព្រះពោធិសត្វកាត់ត្រូវតាមគន្លងធម៌ ព្រះរាជបិតា
តំកល់ព្រះពោធិសត្វឲ្យវិនិច្ឆ័យជាអ្នកកាត់នូវក្តី ចាប់ដើម
តាំងតែអំពីថ្ងៃនោះមក រីឯលាភសក្ការៈនៃព្រាហ្មណ៍នោះក៏
សាបសូន្យ ម្លោះហើយព្រាហ្មណ៍នោះរំពឹងរកទោសតែនឹង
ធ្វើពោធិសត្វ ឯកាធិវសំ មានកាលសម័យថ្ងៃ ១ រាជារី
ព្រះមហាក្សត្រស្តេចផ្ទំក្នុងរាត្រីយល់ឃើញ ស្ថានតាវត្តិង្សទេវ-
លោក ស្តេចក៏មានសេចក្តីប្រាថ្នាចង់បាននូវស្ថានសួគ៌នោះ

ក៏មានបន្ទូលទៅព្រាហ្មណ៍ថា ព្រាហ្មណ ម្នាលព្រាហ្មណ៍អើយ យោ កោចិ បុគ្គលោ រីបុគ្គលឯណាមួយចង់បាននូវសួគ៌ទៅលោកនេះ ឲ្យបុគ្គលនោះឯងយកប្រជុំ ៤ នៃវត្ថុមានមនុស្សនឹងសត្វជាដើមមកបូជាយ័ជ ហេតុនោះបានជាព្រាហ្មណ៍ទូលដូច្នោះ ព្រោះព្រាហ្មណ៍នឹងចង់ឲ្យស្ដេចសម្លាប់ព្រះចន្ទកុមារ ហេតុតែស្ដេចកំឡៅអនុពាលទៅសេពសម្គពនឹងព្រាហ្មណ៍ជាអ្នកកំឡៅអនុពាល ក៏ញុំាងអមាត្យឲ្យចាប់មនុស្សនឹងសត្វមានរាជបុត្រា-បុត្រីជាដើម ម្ល៉ោះហើយអស់មហាជនទាំងឡាយគក់ទ្រូងយំ ជាលដំនុពគ្រប់គ្នាទីទៃ ១ ក៏ជ្រាបដល់មាតាបិតាមកអង្វរមហាក្សត្រនោះក៏ពុំបានឡើយ ; បពិត្រអើយហេតុតែបុណ្យបារមីនៃពោធិសត្វក៏ក្ដៅដល់អាសនាព្រះឥន្ទ្រ ទើបព្រះឥន្ទ្រក៏រមិលមើលដោយទូវព្រះនេត្រមួយពាន់ឃើញកណ្តាហាលព្រាហ្មណ៍នឹងមហាក្សត្រនឹងអស់ផែនពពួកសត្វទាំងឡាយ មានបុត្រីនឹងបុត្រាជាដើម

ទើបព្រះឥន្ទ្រកាន់យកគន្ទូវអន្ទួងដែកនឹងពន្លាកក៏លើកស្ទៅសំដៅ
នឹងកាប់បំបែកក្បាលនៃស្តេចនិងកណ្ឌហាលព្រាហ្មណ៍ ហើយ
ស្រែកគំរាមថា នែ ! ស្តេចកំឡៅអនុពាលជឿតែពាក្យ
ព្រាហ្មណ៍ហើយគិតនឹងសម្លាប់ព្រះចន្ទកុមារ ចូរលែង ៗ ជា
បើមិនលែង អញនឹងកាប់បំបែកក្បាលជា ៧ ភាគ មហា-
ក្សត្រលុះបានស្តាប់ពាក្យសម្តេចអម្រិន្ទ្រគោសីស្រដីគំរាមដូច្នោះ
ក៏មានសេចក្តីភិតភ័យ ហើយអង្វរថាលែងហើយ ៗ ព្រះឥន្ទ្រ
ក៏ហោះទៅកាន់ទេវលោកវិញ មហាក្សត្រដោះអស់មហា-
ជនផងទាំងឡាយ ទើបអស់ជនទាំងឡាយ មានដៃកាន់
យកគន្ទូវដំបង . នឹងដុំថ្មជាដើម ក៏វាយសម្លាប់នៃកណ្ឌហាល-
ព្រាហ្មណ៍ មួយអន្ទើនឹងញាតិទាំងឡាយ ហើយនឹងសម្លាប់
នៃមហាក្សត្រ ទើបពោធិសត្វ ក៏សូមជីវិតបិតា នឹងមហា-
ជន ទើបមហាជនក៏ថ្វាយពោធិសត្វ ប៉ុន្តែឲ្យបណ្តេញទ្រ

ជៀសចេញអំពីនគរ ទៅនៅមួយអន្លើនឹងពួកបែបួស ក៏រៀប
ពោធិសត្វឲ្យសែបសោយរាជសម្បត្តិ មួយអន្លើនឹងនាងចន្ទា-
ទេវី ជាអគ្គមហេសី ប្រកបដោយគន្លងធម៌ លុះលែង
ជាតិអំពីមនុស្សលោក ក៏បានទៅបង្កើតក្នុងសួគ៌ទេវលោក ។
សត្ថា ឥមំ ធម្មទេសនំ អាហរិត្វា បពិត្រ
អើយ រីអង្គសម្តេចជាគ្រូ ព្រះអង្គនាំព្រះធម្មវិសេសទេសនា
ថា ភិក្ខវេ ម្នាលភិក្ខុផងទាំងឡាយអើយ រីទេវទត្តមិន
មែនសម្លាប់តថាគតតែក្នុងជាតិនេះទេ អំពីជាតិមុននាយដ៏ពប
មកដល់ឥឡូវនេះ រីឯកណ្ឌហាលព្រាហ្មណ៍ បានមកជាទេវទត្ត
រីនាងគោតមី បានជានាងស្រីមហាមាយា រីនាងចន្ទាទេវី
បានមកជានាងយសន្ធរា រីចៅវសុលកុមារ បានមកជាពហុល
រីនាងសេលា បានមកជានាងឧប្បលវណ្ណា រីព្រះសុរកុមារ
បានមកជាមហាអានន្ទ រីចៅភមគោត បានមកជាព្រះ
កស្សប រីចៅកន្ទួសេនកុមារបានមកជាព្រះមោគ្គល្លាន រី-

ចៅសុរិយកុមារ បានមកជាព្រះសារីបុត្ត ព្រះឥន្ទ បានមកជាអនុរុទ្ធ ព្រះចន្ទកុមារ គឺអង្គព្រះសម្មាសម្ពុទ្ធ ៗ ចន្ទកុមារជាតកំ និដ្ឋិតំ បពិត្រអើយ នេះយើងនឹងស្រដីសរសើរតំណើរតំណាលកាលព្រះអង្គ ត្រាច់រង្គត់ក្នុងវដ្តសង្សារយោនយកកំណើត កើតជាពោធិសត្វ ១ ព្រះអង្គទ្រង់ព្រះនាមចន្ទកុមារវិញ ជាគំរប់ ៧ ជាតិ និដ្ឋិតំ ស្រេចនូវប្រការទាំងអម្បាលនេះឯងហោង ៗ

+

\+ +

# ៨- នារទជាតក

អហុ រាជា. វិទេហានន្តិ ឥទំ សត្ថា លដ្ឋិ-វនុយ្យានេ វិហរន្តោ ឧរុវេលកស្សបំ អារព្ភ កថេសិ ។ បពិត្រអើយ សម្តេចព្រះសព្វញ្ញូ បានត្រាស់ច្បាស់ប្រាជ្ញាសព្វញ្ញុតញ្ញាណជាបឋមហើយ នោះព្រះអង្គទេសនានូវព្រះធម្មចក្រ ប្រោសបញ្ចវគ្គីយភិក្ខុទាំង ៥ បានដល់ប្រាជ្ញាអរហត្ត បដិសម្ភិទាញាណ ទើបព្រះអង្គយាងទៅកាន់នគររាជគ្រឹះ ដើម្បីនឹងដោះពាក្យប្តេជ្ញានឹងពិម្ពិសាលរាជ ទៅដល់ស្រុក ១ ឈ្មោះឧរុវេលប្រទេស ទេសនាប្រោសនូវមហាឥសី ១ ពាន់ កាន់សាយអគ្គីយ៍ មានមហាឥសីទាំង ៣ ជាធំក្រៃលែង ឈ្មោះឧរុវេលកស្សប ១ ឈ្មោះនទីកស្សប ១ ឈ្មោះគយាកស្សប ១ បានដល់អរហត្ត មគ្គផលគ្រប់គ្នាទៃ ៗ ម្ល៉ោះហើយអស់ពពួកភិក្ខុ

ផងទាំងឡាយសរសើរបុណ្យបារមីថ្វៃ នៃអង្គសម្ដេចព្រះបរម
សាស្ដា លំដាប់នោះព្រះដ៏មានបុណ្យ មានព្រះបន្ទូលទៅ
កាន់ភិក្ខុផងទាំងឡាយថា ភិក្ខុអើយតថាគត ទូន្មាន ទុរុ-
វេលកស្សបនេះ មិនមែនតែក្នុងកាលឥឡូវនេះទេ ភិក្ខុអើយ
នាកាលតថាគតនៅជាព្រហ្ម ១ ក៏អាចឲ្យដំបូន្មាន ទុរុវេល-
កស្សបបានហោង ។ អតីតេ ភិក្ខវេ វិទេហ-
រដ្ឋេ មិថិលាយំ អង្គតិ នាម រាជា រជ្ជំ កា-
រេសិ , ភិក្ខវេ ម្នាលភិក្ខុផងទាំងឡាយអើយ អតីតេ
នាកាលអតីតកន្លងទៅហើយ គ្រានោះមានមហាក្សត្រាធិរាជ
១ ទ្រង់ព្រះនាមព្រះបាទអង្គតិរាជ សោយរាជសម្បត្តិនៅ
នគរមិថិលា ទៀបស្រុកវិទេហរដ្ឋ ប្រកបដោយនូវទស-
ពិធរាជធម៌ មានរាជបុត្រី ១ ឈ្មោះនាងរុជាទេវី ជាកូននៃ
អគ្គមហេសីដ៏ជាធំនៃក្រៃលែង ស្រីស្នំទាំងមួយម៉ឺន ៦ ពាន់
មានសេនាបតី ៣ នាក់ឈ្មោះវិជ័យសេនាបតី ១ សុនាម-

សេនាបតី ១ អាលាតសេនាបតី ១ សឹងជំល្ហាសប្រពៃ ទើប
វិជ័យអមាត្យទូលមហាក្សត្រ ឲ្យទៅរកអ្នកប្រាជ្ញនឹងកាត់សន្និះ
សង្ស័យ មហាក្សត្រថ្វៃត្រាហើយ ក៏សព្វព្រះរាជហឫទ័យ
នឹងចង់ទៅកាន់សំណាក់នៃអ្នកប្រាជ្ញនោះ ទើបអាលាត
សេនាបតី ក្រាបទូលអស់អាថិសេចក្តី ទើបព្រះចក្រីទៅ
កាន់សំណាក់អាចេឡ្យឈ្មោះគុណាកស្សប មួយអន្លើអស់ពពួក
នៃពលមានសេនាបតីជាដើម ទើបមហាក្សត្រ ដណ្ដឹងទូ
អានិសង្សនឹងអាចេឡ្យថា បពិត្រព្រះមហាថេរអើយ `រីបុគ្គល
ឯណាមួយ ជាអ្នកទំនុកបំរុង មានទំនុកបំរុងម្តាយឪពុកជា
ដើម ១ ស្តេចដែលប្រកបទៅដោយទសពិធរាជធម៌ ១ បុគ្គល
ដែលធ្វើឲ្យខុសអំពីគន្លងធម៌ ១ បុគ្គលទាំងអម្បាលនេះ លុះ
ទៅអនាគត តើនឹងសោយផលបុណ្យផលបាបដូចម្តេច ?
បពិត្រអើយ រីឯអាចេឡ្យប្រៀបដូចជាបុគ្គលវង្វេងផ្លូវ ហើយ

មហាក្សត្រដណ្ដឹងរកផ្លូវ ម្ល៉ោះហើយនឹងសំដែងប្រាប់ឯណា ក៏មិនបាន ម្ល៉ោះហើយសំដែងសរសើរទូលបង្គំតាមគុណនោះ ប្រសើរក្រៃលែង សភាវធម៌ទាំងឡាយ ទើបជនទាំង ៣ គឺមហាក្សត្រមួយ , អាលាតសេនាបតី ១ មេកុម្ភទាសី ១ បានស្ដាប់ហើយចូលចិត្តប្រព្រឹត្តតាម តាំងពីដើមអំពីថ្ងៃនោះ ព្រោះហេតុលើកឃើញផលកម្មជារបស់នៃខ្លួន គ្រានោះនាង សុចាវីស្រីថ្ងៃ កាលណាបើនាងជ្រាបសភាព នៃព្រះជនក កាន់លទ្ធិតាមអាចេលដូច្នោះហើយ ចិន្ដេថា ស្រីថ្ងៃនាង រំពឹងគិតពិចារណាថា ឱ ! អ្នកឪពុក អញអើយក៏លុះទៅ ដោយអំណាចកម្មជាទម្ងន់ក្រៃពេក ហើយក៏ចូលទៅកាន់សំ- ណាក់ព្រះវរពជបិតាក្រាបទូលនូវផលបុណ្យ នឹងផលបាបសព្វ គ្រប់ប្រការ មហាក្សត្រាក៏ពុំកាន់យកឡើយ ហើយធីតា នាងក៏ប្រកាសអស់ពពួកនៃទេវតា : ធេវសង្ឃយោ ប- ពិត្រអស់ពពួក ទេវតាផងទាំងឡាយអើយ អ្នកហោងដ៏មាន

ឫទ្ធីតេជះ ខ្លាំងក្រៃ មកជួយដោះព្រះជនកនៃខ្ញុំ ឲ្យរួចចេញអំពីយោបល់ខុសក្រៅគន្លងធម៌ គ្រានោះព្រហ្មនារទពោធិសត្វក៏យកនូវសង្រែកសម្រុកនូវល្អីដាក់នូវមាស រែកហោះចុះអំពីឋានសួគ៌ទេវលោក កាន់យកភេទជាមហាឥសី មានបារមីនោះខ្លាំងក្រៃទៅស្ថិតនៅចំពោះមុខនៃមហាក្សត្រ ស្ថិតឰដ៏ទីនោះហើយទូន្មានអំពីផលបុណ្យ និងផលបាប ដោយអំណាចនៃមាសដែលខ្លួនរែកមក នោះ ឲ្យស្តេចបានលុះដោយនូវប្រាជ្ញានៃខ្លួន · ឲ្យស្តេចលះបង់អំពីមិច្ឆាទិដ្ឋិ ឲ្យកាន់យកនូវសម្មាទិដ្ឋិ លុះក្ស័យជន្មាទៅ បានទៅកើតក្នុងស្ថានសួគ៌ទេវលោក រីនាងសុរូបក្សត្រថៃ ក៏មានសេចក្តីត្រេកអរពេកក្រៃ, បពិត្រអើយរីអគ្គសម្តេចព្រះដ៏ជាគ្រូនាំអតីតនិទានមកសំដែងប្រាប់អស់ពពួក នៃភិក្ខុផងទាំងឡាយស្រេចកាលណាព្រះបរមសាស្តាចារ្យ ទើបប្រជុំមកនូវជាតកថាៈ ភិក្ខវេ ម្នាលភិក្ខុផងទាំងឡាយអើយ រីឯអាលាតសេនាបតីបានមកជា

ទេវទត្ត រីសុនាមអមាត្យបានមកជាកទ្ធដិត្ថេរ វិជ័យអមាត្យបានជាព្រះសារីបុត្តត្ថេរ រីឯដីរកទាសមិញបានជាមោគ្គល្លានត្ថេរ រីឯអាចេលបានជាព្រះសុណ្ណកត្ថេររី នាងសុប្ចារីបានជាអនុទ្ធ-ត្ថេរ រីមហាក្សត្របានជាទុរវេលកស្សប រីព្រះនារទគឺអង្គព្រះសម្មាសម្ពុទ្ធ ណារទជាតកក៏ បពិត្រសប្បុរសផងទាំងឡាយហើយ ចូរត្រង់ចូរត្រាប់ចូរស្តាប់បរិយាយប្រជុំនារទជាតកនេះ ជាគំរប ៨ ជាតិ និត្តិតំ ស្រេចនូវប្រការទាំងអម្បាលនេះ ឯងហោង ។

×

× ×

# ៩ _ ពិធូរជាតក

បណ្ឌុ កីសិយាសិ ទុព្វលាតិ ឥទំ សត្ថា ជេតវនេ វិហរន្តោ បញ្ញាបារមី អារព្ភ កថេសិ ។ កោ សាធកោ បពិត្រសប្បុរសផងទាំងឡាយអើយ សត្ថា នោះ សត្ថាវហោ សត្ថនាយ-កោ ព្រះអង្គជានាយកតែងដឹកនាំសត្វទៅកាន់ព្រះនិ-ព្វាន វិហរន្តោ នោះ ចតូសុ ឥរិយាបថេសុ វិស្សជ្ជាបេន្តោ ក៏ព្រះអង្គសម្រេចនូវឥរិយាបថ ៤ និង កាត់នូវសន្ទិះសង្ស័យចិត្តនៃសត្វទាំងឡាយ ជេតវនេ ក្នុង អារាមឈ្មោះព្រះជេតពន អារព្ភ នោះ អារម្មណំ កត្វា ព្រះអង្គចំពោះធ្វើជាហេតុជាអារម្មណ៍បន្តិច បញ្ញាបា-រមី និងព្រះប្រាជ្ញាបារមី កថេសិ នោះ ទេសេសិ ទើបព្រះអង្គសំដែងព្រះធម៌វិសេសទេសនា ឥទំ វិធូរជា-

តតាំ  នូវវិធូរជាតកនេះ  ធម្មសភាយំ  កថំ  សមុដ្ឋាបេសុំ  គ្រានោះអស់ភិក្ខុផងទាំងឡាយជំនុំគ្នាក្នុងធម្មសភាសាលា  សរសើរបុណ្យបារមីនៃព្រះអង្គជាអស្ចារ្យ  ទឹងរកបុគ្គលណា ១ មកប្រៀបធៀបពុំបាន  ពាក្យនោះក៏មិនបាត់ស្ងាត់ក៏ជ្រាបដល់ព្រះសោតទិព្វថ្លៃ  អំពីភិក្ខុសរសើរនូវបុណ្យបារមីនោះ  ទើបព្រះអង្គនាំអតីតនិទានមកសំដែងថា  ភិក្ខវេ  ម្នាលភិក្ខុផងទាំងឡាយអើយ  អតីតេ  កាលេ  ព្ធដ៏កាលកន្លងទៅហើយ  គ្រានោះមានមហាក្សត្រាធិរាជ ១ ព្រះអង្គ  ទ្រង់ព្រះនាមឈ្មោះព្រះបាទ  ធនញ្ជ័យកោរព្យរាជសោយរាជសម្បត្តិក្នុងនគរឥន្ទបត្ត  មានអមាត្យ ១ ឈ្មោះចៅវិធូរបណ្ឌិត  តែងទឹងប្រដៅធម៌អាថ៌នៃស្តេចនោះ  ដ៏ពិរោះផ្អែមល្ហែម  ជាសណ្តាប់មនុស្សនូវទេវតាផងទាំងឡាយជាច្រើនរកអធិកថ្កើងរុងរឿងក្នុងឥន្ទបត្តបុរីនោះហោង ,  បពិត្រអើយគ្រានោះមានព្រាហ្មណ៍ ៤ នាក់នៅក្នុងនគរពារាណសី  ចេញ

ទៅបួសជាមហាឥសីចំរើនឈានទាំងអភិញ្ញា ក៏បានហោះហើរដើរលើអាកាស មានកាល ១ថ្ងៃក៏មានសេចក្តីប្រាថ្នានឹងចង់បរិភោគនូវវត្ថុវៃប្រែ ហើយចូលបិណ្ឌបាតក្នុងចម្បាកនគរ គ្រានោះមានកុដុម្ពីក៏ ៤ នាក់ក្នុងចម្បាកនគរនោះមានចិត្តជ្រះថ្លាសទ្ធានឹងតាបសនោះក៏និមន្តឆាន់លើផ្ទះនៃអាត្មាតែសព្វថ្ងៃ រីឯតាបសទាំង ៤ អង្គនោះ តាបសមួយទៅកាន់ឧទ្យាននៃស្តេចកោរព្យរាជ , តាបស ១ ទៅកាន់ឋាននៃត្រៃត្រឹង្ស តាបស ១ ទៅកាន់នគរស្តេចវរុណនាគរាជ , តាបស ១ ទៅកាន់ពិភពគ្រុឌរាជ យកសម្បត្តិស្តេចទាំង ៤ មកសំដែងប្រាប់កុដុម្ពីក៏ទាំង ៤ នាក់ ម្ល៉ោះហើយកុដុម្ពីក៏ទាំង ៤ នាក់ក៏មានចិត្តត្រេកអរប្រឹងសង្វាតធ្វើបុណ្យឲ្យទាន ប្រាថ្នាចង់បានសម្បត្តិទាំងអម្បាលនោះ លុះលែងជាតិអំពីមនុស្សលោកបានទៅកើតក្នុងព្រហ្មលោកទាំងអស់ រីឯព្រះបាទធនញ្ជ័យកុមារ លុះ

ឥតអំពីបិតាទៅកាលណា សេពសោយរាជសម្បត្តិបិតនៅក្នុង ទៅតាមដំបូន្មាននៃពោធិសត្វ កំមានចិត្តចង់ចេញទៅចាំសីល គ្រានោះស្តេចទាំង ៤ គឺ : ព្រះឥន្ទ ១ ស្តេចសុបណ្ណគ្រុឌ១ ស្តេចធនញ្ជ័យ ១ វិរុណនាគរាជ ១ ជជែកគ្នាអួតសរសើរ ដែលខ្លួនរក្សាតែដោយខ្លួន ព្រះឥន្ទថាអញលះបង់នូវរាជសម្បត្តិនេះប្រសើរ ស្តេចគ្រុឌថា អញអត់នូវសេចក្តីស្រេកឃ្លាននេះប្រសើរ ស្តេចនាគថា អញមិនស្តាយជីវិតនេះប្រសើរ ស្តេចធនញ្ជ័យថា អញលះបង់នូវរាជសម្បត្តិនេះប្រសើរ, សេចក្តីនេះទឹងរកបុគ្គលឯណាទឹងកាត់ពុំបាន ម្ល៉ោះហើយស្តេចទាំង ៤ ទៅកាន់ពោធិសត្វ ហើយដណ្តឹងនូវអាថិប្រស្នាទាំង ៤ នេះ ព្រះពោធិសត្វកំដោះអស់ប្រស្នា កាត់នូវសន្ទិះសង្ស័យនៃស្តេចទាំង ៤ គ្មានសេសសល់ឡើយ ហើយបូជាពោធិសត្វគ្រប់គ្នាទៅទៃស្រេចហើយទៅកាន់ពិមានជារបស់នៃខ្លួន ៗ គ្រានោះស្តេចវិរុណនាគរាជកំសរសើរដំណើរនៃ

ពោធិសត្វប្រាប់នាងវិមលាទេវី គ្រានោះនាងចង់ស្តាប់ព្រះធម៌វិសេសទេសនានៃពោធិសត្វ ហើយអង្វរស្វាមីដើម្បីនាងនឹងស្តាប់ ម្ល៉ោះហើយស្វាមីអង្វរតេរិយាថា : ⟨ភទ្ទេ⟩ ម្នាលនាងដ៏ចំរើនអើយ ចៅពិធូរអ្នកប្រាជ្ញនោះនឹងបានដោយងាយឯណាបាន នាងនោះបានស្តាប់ហើយស្រដីប្រាប់ទៅវិញទៀតថា ខ្ញុំនេះចង់បរិភោគនូវថ្លើមនៃចៅពិធូរអ្នកប្រាជ្ញនោះ ចាប់ដើមតាំងតែអំពីថ្ងៃនោះ នាងនោះក៏ដេកពុតធ្វើជាឈឺម្ល៉ោះ ហើយស្តេចជាស្វាមីជាទុក្ខក្រៃ គ្រានោះនាងឥរន្ទតីជាបុត្រីក៏ស្អិតស្អាងនៃអាត្មាស្រេចកាលណា ក៏ឡើងទៅឈរលើកំពូលភ្នំឈ្មោះកាលាគិរី មានកំពស់ ៦០ យោជន៍ កាច់កែវរាំលើកំពូលនៃភ្នំនោះ នាងតាំងសច្ចាអធិដ្ឋានថា ⟨ភោន្តេ⟩ បពិត្រអស់លោកដ៏មានឫទ្ធិបារមីផងទាំងឡាយអើយ លោកអើយទៅនាំយកនូវថ្លើមចៅពិធូរឲ្យបានដោយចំណង់ចិត្តមាតា

នៃខ្ញុំ ៗ នឹងយកអ្នកនោះឯងជាស្វាមីដកបណាតែដល់អស់ទៅ
នូវអាយុ គ្រានោះបណកយក្សក៏ជិះមនោម័យហៀរហោះ
កណ្តាលអាកាស ឃើញនាងឥរន្ទវត្តីនៅលើកំពូលភ្នំដូច្នោះ
ហើយ ក៏ចូលទៅជណ្តឹងសព្វគ្រប់ប្រការស្រេចហើយកាល
ណាក៏នាំនាងឥរន្ទវត្តី ទៅកាន់សំណាក់មាតាបិតានៃនាងនោះ
ទើបមាតាបិតាស្រដីប្តេជ្ញាថា បើបណកយក្សនាំថ្លើមទៅពិធូរ
អ្នកប្រាជ្ញមកបានឲ្យនាងនោះបរិភោគ ហើយនាងនឹងឲ្យឥរន្ទ
វត្តីជាករិយានៃបណកយក្សនោះ ម្ល៉ោះហើយបណកយក្ស
នោះជិះមនោម័យទៅភ្នំវិបុលបព៌ត ក៏ដេញពពួកយក្សកាន់
សុទ្ធតែដំបងដែកស្រែកគំរាមរត់ខ្ចាត់ខ្ចាយ ហើយបណកយក្ស
យកនូវកែវមនោ ដើម្បីនឹងមកលេងស្កានឹងព្រះបាទធន-
ញ្ជ័យកោរព្យរាជ គ្រានោះបណកយក្សនឹងព្រះបាទធនញ្ជ័យ
កោរព្យរាជ ក៏ប្តេជ្ញាប្រណាំងស្កានឹងគ្នាស្រេចហើយ ទើប
ក្សត្រទាំងពីរលេងនូវស្កា គ្រានោះបណកយក្សញ៉ាំងស្តេច

ធនញ្ជ័យកោរព្យកជឲ្យតាលបាញ់នូវស្កានោះ ទើបបណក
យក្សនឹងនាំពោធិសត្វទៅកាន់នគរស្ដេចវរុណនាគរាជ ពោធិ-
សត្វអង្វរយក្សបាន ៣ ថ្ងៃ ក៏ផ្ដែផ្ដាំអស់កូនទាំងឡាយមានទៅ
ធម្មបាលជាដើមស្រេចហើយ ទើបបណកយក្សនាំយកទៅ
ដល់ពាក់កណ្ដាលផ្លូវ ទើបបណកយក្សនិម្មិតនៃអាត្មា ឲ្យជា
អស្វាវៀក្រ ដើម្បីនឹងញុំាងពោធិសត្វឲ្យក្ស័យក្នុងទីនោះ ហេតុ
តែបុណ្យបារមីនៃពោធិសត្វ ពុំមានរន្ធត់ដល់ប៉ុនចម្រៀកសក់
ឡើយ ទើបពោធិសត្វសម្ដែងពីកតញ្ញូនឹងអកតញ្ញូនឹងបណក
នោះ បណាកាយក្ខា របណកយក្សនោះបានស្ដាប់
ព្រះធម៌វិសេសទេសនានៃពោធិសត្វហើយ ក៏បូជាកែវមនោហ-
រទៅពោធិសត្វ ហើយនាំពោធិសត្វទៅកាន់នគរវរុណនាគ-
រាជ ទើបពោធិសត្វសំដែងព្រះធម៌វិសេសទេសនាជាសណ្ដាប់
នៃនាគទាំងឡាយមានព្រះបាទវរុណនាគរាជជាដើម មាននាង

វិមលាទេវីជាបំផុត គ្រានោះស្ដេចវរុណនាគរាជ ១ អង្គនឹង
អគ្គមហេសីឲ្យនាងឥរន្ទតីទៅជាភរិយានៃបុណ្ណកយក្ស គ្រា
នោះបុណ្ណកយក្សនាំពោធិសត្វ នឹងនាងឥរន្ទតីមកកាន់ឋានទី-
មាននៃពោធិសត្វវិញ ហើយបុណ្ណកយក្សក៏នាំនាងឥរន្ទតី
ទៅកាន់ប្រាសាទនៃអាត្មា គ្រានោះព្រះបាទធនញ្ជ័យកោ-
រព្យរាជស្ដេចផ្ទំក្នុងរាត្រីនោះ យល់សុបិននិម្មិតយល់ហាក់ដូច
យក្សនាំ ពោធិសត្វត្រឡប់មកវិញ សោ បពុជ្ឈិត្វា បពិត្រ
អើយមហាក្សត្រាធិរាជ លុះតើនចាកក្រឡាបន្ទំកាលណា
ប្រើអមាត្យឲ្យរត់ទៅមើល ព្រះពោធិសត្វនៅទីប្រាសាទនោះ
រីឯអមាត្យក៏នាំយកសេចក្ដីមកក្រាបទូលតាមដំណើរដែលពោ-
ធិសត្វត្រឡប់វិលមកដូច្នោះ ទើបមហាក្សត្រាក៏មានសេចក្ដី-
ត្រេកអរក្រៃ ចាប់ដើមតាំងតែអំពីថ្ងៃនោះទៅកាលណាមហា-
ក្សត្រក៏ស្ថិតនៅក្នុងឱវាទដំបូន្មាននៃពោធិសត្វ, បពិត្រអើយ
មហាក្សត្រាធិរាជក្ដី អស់មហាជនផងទាំងឡាយក្ដី លុះដោយ

នូវដំបូន្មាននៃពោធិសត្វហើយ សឹងសង្វាតធ្វើបុណ្យឲ្យមានចំរើនមេត្តាការនាគ្រប់គ្នាទីទៃៗលុះលែងជាតិអំពីមនុស្សលោកទៅកាលណា បានសោយសម្បត្តិសួគ៌ទេវលោកទាំងអស់ សម្តេចព្រះបរមគ្រូនាំអតីតនិទាន មកសំដែងប្រាប់អស់ភិក្ខុផងស្រេចកាលណា សម្តេចព្រះសាស្តាចារ្យក៏ប្រជុំមកនូវជាតកៈភិក្ខវេ ម្នាលភិក្ខុផងទាំងឡាយអើយ រីឯមាតាបិតាក៏បេរវិលវិលមកបានជាមាតាបិតា, រីឯករិយាធំបានមកជាមាតានៃពហុល, រីឯចៅធម្មបាលបានមកជាពហុល, ស្តេចវរុណនាគរាជបានមកជាព្រះមហាសារីបុត្ត, រីនាងវិមលាទេវី បានមកជានាងឧប្បលវណ្ណា, រីព្រះបាទសុបណ្ណគ្រុឌ បានជាមហាមោគ្គល្លានត្ថេរ, រីព្រះឥន្ទ្រាធិរាជ បានជាអនុរុទ្ធាចារ្យ, រីព្រះបាទធនញ្ជ័យកោរព្យរាជ បានជាព្រះមហាអនន្ទត្ថេរ, រីបរិស័ទបានជាបរិស័ទ, រីចៅពិធូរអ្នកប្រាជ្ញ បានមកជាសម្តេចព្រះ

ពុទ្ធអង្គ ជាត្រៃគពទាំង ៣ ។ បពិត្រអើយអាត្មាភាពសំដែនព្រះធម្មវិសេសទេសនានេះមិញ ក៏ស្រេចដោយនូវប្រការទាំងអម្បាលនេះឯងហោង ។

+

\+ +

# ១០ – វេស្សន្តរជាតក

ផុស្សតិ វរវណាភេតិ ឥទំ សត្ថា កបិលវត្ថុំ ឧបនិស្សាយ និគ្រោធារាមេ វិហរន្តោ ពោក្ខរវស្សំ អារព្ភ កថេសិ ។ សត្ថា នោះ សត្ថវហោ សត្ថនាយកោ ព្រះអង្គជានាយកជាគ្រូប្រសើរ តែងនឹងនាំសត្វទាំងឡាយគៀរប្រមូលបញ្ចូលទៅកាន់អម្រឹតបុរីស្រីមហានគរនិព្វាន ដ៏ជាស្ថានបរមសុខប្រសើរ ៗ វិហរន្តោ កាលគង់នៅ និគ្រោធារាមេ ក្នុងនិគ្រោធារាម ឧបនិស្សាយ ចូលទៅអាស្រ័យយកព្រះបិណ្ឌបាត កបិលវត្ថុ ពីជំស្រុកកបិលពស្តុបុរី អារព្ភ ចំពោះហើយ ពោក្ខរវស្សំ នឹងភ្លៀងសួគ៌១ឈ្មោះបោក្ខរពណ៌ កថេសិ សំដែងហើយ ឥទំ មហាវេស្សន្តរជាតកំ នូវមហាវេស្សន្តរជាតក គាថាបតិប-

ណ្ហិតំ ប្រកបទ្វាគាថា១ពាន់ អាទិគាថាបទេធ ដោយ
បទគាថាមានដូច្នេះជាដើម ជុស្សតិវវវណាកេតិ ឥតិ ថា
ដូច្នេះ ៗ បពិត្រអើយ កាលព្រះអង្គត្រាស់បឋមនោះស្តេច
យាងទៅកាន់ព្រៃមិគទាយពនប្រោសបញ្ចវគ្គិយនឹងព្រាហ្មណ៍
១៨ កោដ្ឋជាសួរេចហើយ ទើបព្រះអង្គយាងទៅកាន់នគររាជ-
គ្រឹះដោយពាក្យប្តេជ្ញានឹងព្រះបាទកុត្តរាជជាសួរេចហើយ ទើប
ព្រះអង្គបំបួសរាជអមាត្យធំ ១ម៉ឺនដែលព្រះវររាជបិតាប្រើឲ្យទៅ
និមន្តនោះក៏ជាសួរេចហើយ ទើបព្រះអង្គយាងទៅប្រោសព្រះ
ញាតិ មានព្រះបាទស្រីសុទ្ធោទនមហារាជជាដើមជាសួរេច
ហើយ ទើបព្រះអង្គនាំអតីតនិទានមកសំដែងប្រាប់ពពួកភិក្ខុ
ថា: អតីតេ ភិក្ខវេ សិវិរដ្ឋេ ជេតុត្តរនគរេ
សិវិមហារាជា នាម រជ្ជំ ការេសិ ។ ភិក្ខវេ
ម្នាលភិក្ខុផងទាំងឡាយអើយ អតីតេ ក្នុងអតីតកាលកន្លង
ទៅហើយ ត្រានោះមានមហាក្សត្រាធិរាជ ១អង្គទ្រង់ព្រះនាម

ព្រះបាទសិរិមហារាជ សោយរាជសម្បត្តិក្នុងស្រុកជេតុត្តរនគរ មានព្រះរាជបុត្រ១ ឈ្មោះសញ្ជ័យកុមារ លុះព្រះជន្មបាន១៦ ឆ្នាំ ទើបព្រះវរបិតាក៏អភិសេកឲ្យសោយរាជសម្បត្តិ ១អន្លើនឹងព្រះរាជបុត្រីនៃស្តេចទ្រង់ព្រះនាម ឈ្មោះព្រះបាទមទ្ទរាជ ឈ្មោះនាងសុបាសុប្បតីទេវីនឹងស្រីព្រះស្នំធំ១ម៉ឺន៦ពាន់ ៗ បពិត្រអើយ នាងសុបារសុប្បតីនោះ កាលក្នុងសាសនាព្រះពុទ្ធវិបស្សី នាងបានឲ្យខ្ទឹមច័ន្ទន៍ ប្អូនស្រីនាងបានឲ្យសុពណ៌មាលាមាស ដែលព្រះវរបិតាទ្រង់ព្រះប្រទានឲ្យ ហើយនាងសច្ចាប្រាថ្នាឲ្យបានជាពុទ្ធមាតា នាងជាប្អូនស្រីឲ្យបានជាព្រះអរហត្តលុះអស់អាយុអំពីមនុស្សលោកក៏បានទៅកើតក្នុងទេវលោក នាងជាប្អូនស្រីលុះដល់សាសនាព្រះពុទ្ធកស្សប នាងក៏បានសម្រេចព្រះអរហត្ត នាងជាបងលុះអំណើះទៅមុខ ៩០ កប្ប នឹងបានជានាងស្រីមហាមាយា កាលដែលនាងច្យុតចុះចាកអំពីឋានទេវលោកនោះបានទទួលពរអំពីព្រះឥន្ទ្រទាំង ១០ ប្រការ

ដូចមានពារៈព្រះបាលីថា ៈ វរញ្ញា ដូច្នេះជាដើម មាន ឫ
ទ្ធិធំ ជាទីបំផុត ៗ ហើយស្ដេចច្យុតស្រេចចុះមកចាប
បដិសន្ធិក្នុងគភ៌អគ្គមហេសីនៃព្រះបាទមធុរាជ លុះចំរើនធំឡើង
មានរូបឆោមល្អ បីដូចស្រីទេពអប្សរបរិកញ្ញា បានមកជាអគ្គម-
ហេសីនៃចៅសញ្ជ័យកុមារ គ្រានោះព្រះឥន្ទ្រនិមន្តពោធិសត្វ
ឲ្យមកចាប់បដិសន្ធិក្នុងគភ៌នៃនាងសុបាសុប្បតី លុះដល់គំរប់
ខែ ១០ នាងចេញទៅកាន់ផ្លូវឈ្មួញធំ១អន្ទើទីងសុំពណិសិរិ
កា ប្រសូតពោធិសត្វក្នុងទីនោះ ហេតុតែបារមីនឹងឲ្យបង្កើត
ជាអស្ចារ្យក៏សូមយកនូវមាស១សែនដំឡឹងអំពីមាតាឲ្យជាទាន
១រំពេចនោះឯង ហើយសន្មតនាមឲ្យឈ្មោះហៅព្រះ វេស្ស-
ន្តរកុមារត្បិតព្រះពោធិសត្វកើតក្នុងផ្លូវឈ្មួញនោះហោង ៗ
ក្នុងថ្ងៃនោះមានមេដំរី១នាំកូនដំរីស១ឈ្មោះបច្ច័យនាគទ្រមក
ថ្វាយព្រះពោធិសត្វក្នុងថ្ងៃនោះ លុះដល់ពោធិសត្វចំរើនព្រះ
ជន្មវស្សាបាន ១៦វស្សា ព្រះវររាជបិតាក៏នាំយកនូវធីតានៃ

សក្យរាជឈ្មោះនាងមទ្រីមកអភិសេក លុះយូរបន្តិចទៅក៏បានទូវព្រះរាជបុត្រា ១ ឈ្មោះជាលី រាជបុត្រី ១ ឈ្មោះនាងក្រស្នា ពោធិសត្វឲ្យសោយរាជសម្បត្តិ១អន្លើដោយស្រីទាំង ១ម៉ឺន៦ពាន់, គ្រានោះមានឧគរស្តេច១ឈ្មោះកលិង្គរាស្ត្រកើតទុរ្ភិក្សអត់បាយ ទើបមហាជនទាំងឡាយ ជំនុំគ្នានឹងចង់បានទូវដំរីនោះ មហាក្សត្រក៏ប្រើព្រាហ្មណ៍ទាំង៨នាក់ឲ្យទៅសូមយកទូវដំរីបច្ច័យនាគនៃពោធិសត្វ គ្រានោះពោធិសត្វគង់លើដំរី លុះព្រាហ្មណ៍ទាំង៨ទៅដល់ក៏សូមទូវដំរីនោះ ពោធិ-សត្វទ្រង់ព្រះរាជទានឲ្យទៅព្រាហ្មណ៍ទាំង ៨ នាក់ ទើបព្រាហ្មណ៍ក៏នាំយកទូវដំរីនោះទៅ , គ្រានោះអ្នកស្រុកស្រីពិ-រាស្ត្រទាំងឡាយក៏កើតកោលាហល នឹងពោធិសត្វឲ្យដំរីបច្ច័យនាគទៅព្រាហ្មណ៍ ក៏យកសេចក្តីនេះចូលក្រាបទូលដល់ព្រះវររាជបិតានឹងបណ្តេញពោធិសត្វឲ្យចេញអំពីនគរ គ្រានោះ

ព្រះវរបិតា ឲ្យពតិមានទៅពោធិសត្វសព្វគ្រប់ប្រការស្រេច កាលណា ទើបពោធិសត្វក៏នាំអគ្គមហេសីនិងបុត្រាបុត្រីទៅ កាន់ភ្នំគិរីវង្កត គ្រានោះព្រះឥន្ទ្រាធិរាជប្រើវិស្សកម្មទេវបុត្រ ឲ្យមកនិម្មិតជាអាស្រមបទសាលាមានទាំងគ្រឿងបរិក្ខារសំពប់ អ្នកបួស ហើយប្រកាសថា បើអ្នកឯណាមានប្រាថ្នាដើម្បី នឹងបួស ចូរឲ្យយកគ្រឿងបរិក្ខារនេះ ៗ បពិត្រអើយគ្រានោះ ពោធិសត្វយកនូវសំពត់ជ្រលក់ទឹកអម្ចត់ស្លៀក យកស្បែក ខ្លាឃ្មុំទាំងក្រចកបង់ក ស្ពាយធៀង នាងមទ្រីព្រមទាំងបុត្រា បុត្រីបួសជាមហាឫសីទាំងអស់ , នាងមទ្រី កាលបើនាង ចូលទៅក្នុងព្រៃរកផ្លែឈើនូវមើមឈើ តែងយកព្រះរាជបុត្រ ទាំងពីរមកផ្ញើនឹងព្រះបាទស្រីវេស្សន្តរ ហើយនាងបំរើតែសព្វ ថ្ងៃ ៗ ឯកោ ព្រាហ្មណោ មានព្រាហ្មណ៍ ១ ឈ្មោះ ជូជកព្រាហ្មណ៍ ជាអ្នកដើរសូមទានបានមាស ១ ពាន់ ដំឡើង យកទៅផ្ញើក្នុងត្រកូលព្រាហ្មណ៍ ១ រីឯត្រកូលព្រាហ្មណ៍នោះ

ក៏ចាយកាយមាសនោះអស់ទៅ ក៏ឲ្យនាងអមិត្តតាបនាជាភរិយា
នៃតាជូជក នាងនោះប្រតិបត្តន៍ល្អប្រពៃក្រៃ ៗ រីឯព្រាហ្មណ៍
កម្លោះទាំងឡាយឃើញនាងអមិត្តតា ប្រតិបត្តន៍តាជូជកដូច្នោះ
ក៏ស្រដីជេរបន្ទោសប្រពន្ធនៃអាត្មាគ្រប់គ្នាទៃ ៗ ម្លោះហើយ
ស្រីទាំងឡាយព្រួតគ្នាវាយនាងអមិត្តតា រីនាងអមិត្តតាបនាក៏
អំពុកឲ្យតាជូជករកខ្ញុំបម្រើនៃអាត្មា គ្រានោះនាងមទ្រីទ្រង់សុ-
បិនទិមិត្តយល់ហាក់ដូចមានតាចាស់១នាក់ មកពុះទ្រូងរូងយក
ថ្លើមនៃនាង នាងចូលទៅជណ្ដាំងព្រះវេស្សន្តរ ព្រះអង្គពុំបរតា
ឡើយ ៗ គ្រានោះជូជកក៏ដើរត្រាច់ទៅក្នុងគិរីវង្កត ដើម្បីនឹង
សូមយកពជបុត្រនៃព្រះបាទស្រីវេស្សន្តរ បានជួបប្រទះនឹង
ចេត្តបុត្រ១អន្ទើនឹងឆ្កែរបស់ខ្លួន តាជូជកក៏ដោះសារលួងអាត្មា
អំពីសេចក្ដីស្លាប់ ហើយត្រាច់ទៅកាន់ក្នុងគិរីវង្កត បានជួបនឹង
អច្ចុតឥសីសិទ្ធទ្រង់ក្រឹត្យមង្គល តាជូជកស្រដីនូវពាក្យមុសា

វាទ អ្នកគម្រេះនៃតាគ្នាជាអ្នកព្រឹទ្ធាចារ្យ ម៉្លោះហើយតាបស ឥសីលើកដៃចង្អុលប្រាប់ផ្លូវទៅកាន់អាស្រមបទ ព្រះវេស្សន្តរ ក្នុងវេលានោះនាងមទ្រីក៏យកខ្លូវសៅជ្រែក ដងរែកនឹងចំ-ពក់ ចបជីកចូលទៅក្នុងព្រៃ ដើម្បីនឹងនាំមក នូវផ្លែឈើមើមឈើមកឲ្យព្រះវេស្សន្តរនឹងរាជបុត្រទាំងពីរ ។ លុះតាជូជកទៅដល់កាលណា ក៏សូមយកនូវរាជបុត្រទាំងពីរ គ្រានោះទេវតាទាំងបី ក៏និម្មិតនៃតាគ្នាជារាជសីហ, ខ្លាធំ-ខ្លាដំបង មកក្រាបក្រោមនៅលើផ្លូវ ដើម្បីនឹងមិនឲ្យនាងទៅបាន ។ បពិត្រអើយមុខគួរតែអធិប្លាពរាជបុត្រទាំងពីរ លុះព្រឹបតានឹងឲ្យអាត្មាទៅព្រាហ្មណ៍ក៏ភិតភ័យញាប់ញ័ររន្ធត់ស្ញើរបាត់ស្មារតី នាំប្អូនស្រីរត់ចូលទៅក្នុងស្រះ យកស្លឹកឈូកគ្របលើក្បាល គ្រានោះតាជូជកក៏រមិលមើលព្រះរាជបុត្រមិនឃើញក៏ក្តិះគិះដៀលទៅព្រះវេស្សន្តរ គ្រានោះពោធិសត្វមានព្រះបន្ទូលហៅព្រះរាជបុត្រដោយបទព្រះបាលីថា : ឯហិ តាត បិយ បុត្តកា

ម្នាលកូនស្ងួនសំឡាញ់មាសឪពុកអើយ ចូរអ្នកមកអាយឪពុក នឹងឲ្យអ្នកទៅតាដូដកព្រាហ្មណ៍ នឹងវិញយកប្រាជ្ញាសពេជ្ញ-តញ្ញាណ នឹងបាននាំសត្វជាក់ដល់ត្រើយព្រះនិព្វាន ចូលអ្នកជាស្ពានជាយាននៃបិតា ជាលីបានស្តាប់ពាក្យបិតាហៅដូច្នោះកាលណា ក៏លើកស្លឹកឈូកអំពីសិរសាឡើងមកឧបបាទនៃបិតាខាងស្តាំ ទើបព្រះវរបិតាដណ្តឹងថា ក្រស្នាតើនាងនៅឯណា ? ទើបជាលីទូលថាជាកណ្តាល ។ ព្រះបិតាអើយ ធម្មតាសត្វពុំទាន់កាត់នូវកម្មកិលេសបាន តែមានទុក្ខដល់ប្រាណក៏មានភិតភ័យញាប់ញ័ររន្ធត់ ស្មើនឹងបាត់ស្មារតីក្បីណក្ស័យនៃព្រះជន្ម នាងក្រស្នាបានឮពាក្យបិតាដណ្តឹងដូច្នោះហើយ ក៏ឡើងមកឧបបាទនៃបិតាខាងឆ្វេង

គ្រានោះវេស្សន្តរក៏នាំពជបុត្រទាំងពីរមកឲ្យតាដូដក លុះតាដូដកនាំហួសបន្តិចទៅ មទ្រីនាងតាំងអធិដ្ឋានថា ។ អស់

លោកទេវតាដែលនៅរក្សាក្នុងព្រៃនេះ  សូមលោកអាសូរខ្ញុំ
មទ្រី ត្បិតនឹងនាំអាហារទៅឲ្យក្សត្រទាំង ៣ ឥឡូវស្មើនេះ
ហើយ ម៉្លេះសូមអ្នកនឹងទន្ទឹងមើលផ្លូវខ្ញុំ មទ្រី  ឱ ! អស់
លោកទេវតាអើយ បូរអ្នកអាសូរករុណាបើកផ្លូវខ្ញុំ គ្រានោះ
ទេវតាក៏បើកផ្លូវឲ្យនាងមក  លុះដល់អាស្រមសាលាក៏ដាក់
អម្រែកអំពីស្មា គេបុត្រទាំងពីរពុំយល់ ទៅដណ្ដឹងព្រះវេស្ស-
ន្ដរ ៗ ពុំចរចាឡើយ ម៉្លោះហើយនាងក៏គក់ព្រះឱរា ទួញថា :
ឱកូនគូរកំសត់មាសម្ដាយអើយ អ្នកបាត់ទៅឯណា  នាងក៏
រត់រកក្នុងព្រៃព្រឹក្សា ស្រែកដង្ហោយហៅបុត្រាបុត្រី បក្សាបក្សី
ក៏ភ្ញាក់ផ្អើលរត់ទៅដោយទិសទីទៃ ៗ ក្សត្រីថ្វីនាងរកក៏ពុំយល់
ឡើយ  ហើយនាងក៏ប្រះប្រាណសន្ធប់ក្នុងទីចំពោះមុខនៃព្រះ
វេស្សន្ដរ  គ្រានោះព្រះវេស្សន្ដរឃើញនាងមទ្រីប្រះប្រាណ
សន្ធប់ដូច្នោះហើយ  ស្ដេចទ្រង់ព្រះរិះយោគសោយសោកថា:
ឱ ! មទ្រីកាន់អើយ នាងមានរូបល្អគ្រប់អវយវៈគ្មានខ្ចោះត្រង់

ណា ឥឡូវនេះនាងក៏មកកៀណក្បែរព្រះជន្នាក្នុងព្រៃស្ងាត់ ជ្រងំតែម្នាក់ឯង នាងនៅក្នុងគុកទៅក៏ បងនឹងលើកសពនៃ-នាង មួយវិញទៀតកូនតាំងពីដែលនាងរក្សាក៏ពុំបានធ្វើអនុ-មោទនា ទុ! មទ្រីនាងអើយកូនតាំងពីដែលអញឲ្យទានទៅតាជូជកព្រាហ្មណ៍នោះ លុះទៅអនាគតក៏សូមឲ្យនាងបានជាកន្លៃស្រពេជ្ញតាញាណ ។ សា បតុជ្ឈិត្វា គ្រានោះនាងមទ្រីលុះដឹងព្រះស្វារតីកាលណា ឮព្រះបន្ទូលព្រះបាទវេស្ស-ន្តរជូហ្នោះកូ ហើយនាងក៏មានសេចក្តីត្រេកអរ សោមនស្សានឹងផលានិសង្ឃ នាងនឹងបានជាកន្លៃស្រពេជ្ញ ក៏ទទួលអនុ-មោទនាថា សាធុ ៗ បពិត្រព្រះស្វាមីអើយ អ្នកពោលនូវពាក្យពីរោះពេក ចូរអ្នកកុំសោយសោកនឹងខ្ញុំមទ្រីឡើយ ខ្ញុំនឹងអនុមោទនាផលានិសង្ស ដែលព្រះអង្គឲ្យព្រះរាជបុត្រទាំងពីរទៅតាជូជក ក៏សូមឲ្យបានជាកន្លៃស្រពេជ្ញនៃព្រះអង្គ ទៅ

ញុំងអនាគត ; បពិត្រអើយក្សត្រទាំងពីរកំស្រមក្សាន្តព្រះ
រាជហឫទ័យ ចាប់ដើមតាំងពីថ្ងៃនោះ ; គ្រានោះតាជូជក
នាំកុមារទាំងពីរទៅ ដោយហេតុតែអំណាចនៃទេវតារក្សា
កុមារទាំងពីរ ក៏នាំតាជូជកឲ្យវង្វេងផ្លូវទៅឯនគរព្រះបាទស្រី
សញ្ជ័យជាជីតានៃកុមារទាំងពីរ ព្រះបាទស្រីសញ្ជ័យយក
មាសឆ្អិនពីរពាន់ដំឡឹង ១អន្លើនឹងទ្រព្យទាំងពួងទិញកុមារទាំង
ពីរ ពីតាជូជកព្រាហ្មណ៍ ហើយញុំាងអមាត្យឲ្យរៀបពល១២
អក្ខោភិនី ទៅជាលីជាអ្នកនាំផ្លូវ ស្ដេចឲ្យរៀបអស់ស្បៀង
អាហារជប់លៀងនៃតាជូជកព្រាហ្មណ៍ច្រើនក្រៃ រីតាជូជក
សោតហេតុតែកយដំប្រំណាក់កុមារទាំងពីរ បរិភោគនូវអាហារ
ពាល់តែបែកពោះក្សណក្ស័យនៃជន្មាទៅ គ្រានោះព្រះបាទស្រី
សញ្ជ័យនឹងពល ១២អក្ខោភិនី មានទៅជាលីជាអ្នកបង្ហាញផ្លូវ
ទៅកាន់ភ្នំគិរីវង្កត អស់រយៈកាល១ខែគត់ទើបបានដល់ទៅភ្នំ
គិរីវង្កតនោះ ឯមហាក្សត្រទាំង៦ព្រះអង្គទ្រង់វិយោគសោយ

សោកសន្ទប់ពុំដឹងព្រះស្មារតីឡើយ ទើបព្រះឥន្ទ្របង្អុរទឹកភ្លៀងពោក្ខរពណ៌ ស្រោចស្រពក្សត្រទាំង៦ព្រះអង្គឲ្យមានស្មារតីឡើង, គ្រានោះព្រះម្ចាស់ស្រីសញ្ជ័យសូមទោសនឹងពោធិសត្វហើយ ក៏អញ្ជើញពោធិសត្វឲ្យមកសោយរាជ្យសម្បត្តិដូចដែលវិញ បពិត្រអើយព្រះវេស្សន្តរជាមហាបុរសនៅក្នុងព្រៃបើនឹងគណនាជាខែបាន៧ខែបាយ ក៏ត្រឡប់វិលមកសោយរាជសម្បត្តិក្នុងនគរវិញ កាលដែលពោធិសត្វត្រឡប់វិលមកដល់ព្រះនគរក៏ព្រះឥន្ទ្របង្អុរភ្លៀងរតន៍ទាំង៧ ធ្លាក់ចុះត្រឹមចង្កេះ ត្រឹមជង្គង់សព្វទិសទីទៃ ។ ។ សម្តេចព្រះពុទ្ធអង្គសំដែងថ្វាយព្រះធម៌វិសេសទេសនាក្នុងវេស្សន្តរជាតកមិញ ដ៏ប្រដាប់ទូវគាថា១ពាន់ជាស្រេចហើយ ទើបព្រះអង្គប្រជុំមកនូវជាតកដោយបទព្រះគាថាដូច្នេះ តទា ផុជតោ ទេវទត្តោ អហោសិ រីឯតាជូជកបេរិលវិលមកបានជាទេវ-

ទត្ត ។ ឯនាងអមិត្តតាបនាបានមកជានាងចិញ្ចមាណវិកា ។ ឯចេតបុត្របានមកជាមហាបុណ្ណត្ថេរ ។ ឯអច្ចុតតាបសឥសីបានជាសារីបុត្តត្ថេរ ។ ឯព្រះឥន្ទបានមកជាអនុរុទ្ធាចារ្យ ។ ឯព្រះបាទស្រីសញ្ជ័យបានជាព្រះបាទស្រីសុទ្ធោទនមហារាជ ។ ឯនាងសុបាសុប្បតីបានមកជានាងមហាមាយា ។ ឯនាងមទ្រីបានមកជានាងយសន្ធពិម្ពា ។ ឯចៅជាលីបានមកជារាហុលត្ថេរ ។ ឯនាងក្រស្នាបានមកជានាងឧប្បលវណ្ណាថេរី ។ ឯព្រះវេស្សន្តរបានមកជាសម្តេចព្រះពុទ្ធអង្គ ត្រាស់ប្រាជ្ញាសព្វេជ្ញតាញាណ ។

វេស្សន្តរជាតកាំ និដ្ឋិតំ ។ បពិត្រអើយអាត្មាសំដែងថ្វាយព្រះធម៌វិសេសទេសនា វេស្សន្តរជាតកនេះមិញដ៏ប្រដាប់នូវព្រះគាថា មួយពាន់ក៏ចូលជាបច្ច័យនៃទាយកទា-

យិកា ឧបាសក ឧបាសិកា និដ្ឋិតា ក៏ចប់បរិបូណ៌សមគួរ
ដល់វេលាអម្បាលនេះឯងហោង ។

–ចប់ ទសជាតកក៏សង្ខេប–

មានលក់ដុំ និង រាយ

នៅតូបលេខ 58 - 59 ផ្សារអូរឫស្សី

0001681
ANGKOR THOM BOOKSHOP
$ 0.60